00287379

D138/1/1

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ ) |
| ដាក់ទៅ: | អង្គបុរេជំនុំជម្រះ |
| ថ្ងៃដាក់: | ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩ |
| ភាគីអ្នកដាក់: | សហមេធាវីរបស់លោក អៀង សារី |
| ភាសាដើម: | អង់គ្លេស |
| ប្រភេទឯកសារ: | **សាធារណៈ** |

---

# បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីការរំលោភបំពានការសម្ងាត់នៃកិច្ចស៊ើបសួរ និងសំណើសុំដាក់កាលបរិច្ឆេទដាក់ឯកសារជាបន្ទាន់ និង សវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈ

---

**អ្នកដាក់ឯកសារ៖**

**សហមេធាវីរបស់លោក អៀង សារី**

លោក អាង ឧត្តម

លោក Michael G. KARNAVAS

**អ្នកទទួលឯកសារ៖**

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ន័យ ថុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Katinka LAHUIS

ចៅក្រម Rowan DOWNING

សហព្រះរាជអាជ្ញា

លោកស្រី ជា លាង

លោក Robert PETIT

**ឯកសារដើម**

ORIGINAL DOCUMENT/DOCUMENT ORIGINAL

ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 10 / 03 / 2009

ម៉ោង (Time/Heure): 15:55

មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

CERTIFIED COPY/COPIE CERTIFIÉE CONFORME

ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 11 / MAR / 2009

មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.Fuy

## I. សេចក្តីផ្តើម

1. សហមេធាវីរបស់លោក **អៀង សារី** គឺលោក **អាង ឧត្តម** និងលោក **ម៉ៃឃើល ខាណាវ៉ាស់** (Michael G. KARNAVAS) ("មេធាវីការពារក្តី") សូមដាក់ជូននូវបណ្តឹងឧទ្ធរណ៍នេះប្រឆាំងនឹង "ដីកាសម្រេចអំពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ" ("ដីកាស្តីពីការសម្ងាត់") ដែលចេញដោយការិយាល័យសហចៅក្រមស៊ើបអង្កេត("ក.ស.ច.ស") កាលពីថ្ងៃទី ៣ មីនា ២០០៩[1]។ ខណៈដែលមេធាវីការពារក្តី ស្វាគមន៍នូវការជជែកវែកញែកអំពីតម្លាភាពដែលត្រូវបានអុចអាលតាមរយៈដីកាស្តីពីការសម្ងាត់[2] ដីកានេះគឺជាក់ស្តែងសំអាងលើការភ័ន្តច្រលំ លើកំហុសឆ្គងខាងហេតុ និងលើកង្វះខាតនៃសំអាងហេតុផ្នែកច្បាប់ ដែលទាំងអស់នេះធ្វើខូចខាតយ៉ាងធ្ងន់ធ្ងរដល់គោលការណ៍ដែលថា "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយ ... ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និង<u>កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព</u>"[3] ។ មានតែទុកជាមោឃៈនូវ ដីកាស្តីពីការសម្ងាត់ ហើយអនុញ្ញាតអោយ មេធាវីការពារក្តី រក្សាទុកនូវគេហទំព័រមួយ នៅគ្រប់ពេលវេលានៃកិច្ចដំណើរការនីតិវិធីដើម្បីដាក់បង្ហាញនូវ*ការដាក់ឯកសារជាសាធារណៈ*នានារបស់ មេធាវីការពារក្តី នៅចំពោះមុខ អ.វ.ត.ក តែប៉ុណ្ណោះ នោះទើបអង្គបុរេជំនុំជម្រះ នឹងមានលទ្ធភាពដើម្បីធានាថា មិនមានផលប៉ះពាល់ទៅលើសិទ្ធិរបស់ភាគីនីមួយៗ នៅចំពោះមុខកិច្ចដំណើរការនីតិវិធី ដើម្បីតស៊ូមតិអំពីសេរីភាពរបស់ខ្លួនដោយសេរី ជាចំហ និងមានតម្លាភាព។

## II. សវតានៃអង្គហេតុ

2. ពេញមួយរយៈពេលនៃកិច្ចស៊ើបសួរ មេធាវីការពារក្តីបានបើកចំហរ និងធ្វើអោយមានតម្លាភាពយ៉ាង

---

[1] *ករណី អៀង សារី* សំណុំលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស ដីកាសម្រេចស្តីពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ ចុះថ្ងៃទី ៣ មីនា ២០០៩។

[2] *សូមមើល* ជាឧទាហរណ៍ សេចក្តីថ្លែងការណ៍រួមរបស់ អង្គការសង្គមស៊ីវិល មានចំណងជើងថា ក្តីបារម្ភអំពីការរឹតត្បិតលើតម្លាភាព ដែលបណ្តាលមកពីដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីការរំលោភបំពានលើភាពសម្ងាត់នៃកិច្ចស៊ើបសួរ ធ្វើនៅភ្នំពេញ ថ្ងៃទី ៦ មីនា ២០០៩ ដែលបានភ្ជាប់មកជាមួយនៅក្នុងឧបសម្ព័ន្ធ ក ("សេចក្តីថ្លែងការណ៍រួមរបស់សង្គមស៊ីវិល")។

[3] វិធាន ២១(១) (គូសបញ្ជាក់បន្ថែម)។

ពេញលេញនៅក្នុងការរិះគន់របស់ខ្លួនទៅលើភាពមិនចាំបាច់ និងកម្រិតផ្ទុយគ្នានៃការសម្ងាត់នៃកិច្ចស៊ើបសួរ។ អមជាមួយបញ្ហានៃភាពសម្ងាត់គឺ បញ្ហានៃការយឺតយ៉ាវដែលគួរអោយចាប់អារម្មណ៍នានារវាងពេលដែលឯកសារត្រូវបានដាក់ដោយភាគីមួយ និងពេលដែលការដាក់ឯកសារនោះត្រូវបានគេជូនដំណឹងដល់គូភាគីនានា[4]។ ខណៈដែលពេលវេលានៃការដាក់ឯកសារគឺជាផ្នែកដែលមិនអាចញែកពីគ្នាបានរវាងយុទ្ធសាស្ត្រ និងកិច្ចកលរបស់ភាគី ការយឺតយ៉ាវដែលមិនអាចពន្យល់បាននៅក្នុងការជូនដំណឹងអំពីឯកសារដល់គូភាគី ដែលវាគឺជាដំណើរការរដ្ឋបាលសុទ្ធសាធុហើយចំណាយពេលតែប៉ុន្មានម៉ោងប៉ុណ្ណោះនៅតុលាការ *ចំពោះកិច្ច* (*ad hoc*)ភាគច្រើន ធ្វើអោយគេមានគំនិតស្រពេចស្រពិលថាការដាក់ឯកសារទាំងនេះកំពុងត្រូវបានគេរឹតត្បិត ឬត្រូវពន្យារពេលដោយសារមូលហេតុមិនសមស្រប។ មេធាវីការពារក្តីបានជូនដំណឹងជាបន្តបន្ទាប់ទៅកាន់ ក.ស.ច.ស អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាលអំពីក្តីបារម្ភរបស់ មេធាវីការពារក្តី ទាក់ទងទៅនឹងការអន្តរាគមន៍មិនត្រឹមត្រូវរបស់តុលាការទៅក្នុងអង្គភាពនានារបស់តុលាការដូចជា ផ្នែកគ្រប់គ្រងតុលាការជាដើម ។

3. នៅថ្ងៃទី ៣ ធ្នូ ២០០៨ មេធាវីការពារក្តី បានសសេរលិខិតមួយច្បាប់ទៅកាន់ប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាល ដោយរៀបរាប់លំអិតអំពីក្តីកង្វល់នានារបស់ខ្លួនទាក់ទងទៅនឹងការប៉ុនប៉ងដែលមិនបានសម្រេចដើម្បីដាក់ឯកសារ ដើម្បីជាផ្នែកមួយនៃកំណត់ត្រា នូវអំណះអំណាងស្តីពី ការទទួលខុសត្រូវព្រហ្មទណ្ឌនៃ សហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងសំណុំរឿងរបស់ **ឌុច** [5]។ ដោយបានជួបជាមួយនឹង អនុប្រធានការិយាល័យរដ្ឋបាលនាថ្ងៃទី ១១ ធ្នូ ២០០៨ ដើម្បីពិភាក្សាអំពីក្តីបារម្ភដែលមានចុះនៅក្នុងលិខិតនោះមក នាថ្ងៃទី ១៨ ធ្នូ ២០០៨ មេធាវីការពារក្តី បានសរសេរលិខិតមួយច្បាប់ទៀតទៅកាន់ប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាល និងប្រធានអង្គភាពគ្រប់គ្រងតុលាការដើម្បីធ្វើអោយរឹងមាំនូវក្តីកង្វល់នានារបស់ខ្លួនដែលបានសំដែងនៅក្នុងលិខិតដើមនោះ។ នៅក្នុងលិខិតនេះ មេធាវីការពារក្តី បានជូនដំណឹងយ៉ាងច្បាស់ក្រឡែតដល់ការិយាល័យរដ្ឋបាលថា *"ដើម្បីបង្ហាញពីការប្តេជ្ញាចិត្តរបស់យើងខ្ញុំចំពោះដំណើរការប្រកបដោយយុត្តិធម៌ និង តម្លាភាពនៅអង្គជំនុំជម្រះវិសាមញ្ញ យើងខ្ញុំសូមគូសបញ្ជាក់ឡើងវិញនូវចេតនារបស់យើង ដែលបានសម្តែងនៅឯកិច្ចប្រជុំដើម្បីបង្កើតគេហទំព័រ*

---

[4] *សូមមើល* ឧបសម្ព័ន្ធ ខ៖ បញ្ជីរាយនាមការដាក់ឯកសារជ្រើសរើសមួយចំនួននៅចំពោះមុខ ក.ស.ច.ស និង អង្គបុរេជំនុំជម្រះ និងរយៈពេលប្រើប្រាស់រវាងថ្ងៃដាក់ឯកសារ និងថ្ងៃជូនដំណឹងអំពីឯកសារ ។

[5] *សូមមើល* ឧបសម្ព័ន្ធ គ៖ លិខិតទៅកាន់ឯ.ឧ. ស៊ាន វិសុទ្ធ និងឯ.ឧ. Knut ROSANDHAUG ដែលមានចំណងជើងថា "ការជ្រែតជ្រែកមិនត្រឹមត្រូវដោយចៅក្រមនៃបុរេជំនុំជម្រះទៅក្នុងកិច្ចការរដ្ឋបាលរបស់ផ្នែកគ្រប់គ្រងតុលាការ" ចុះថ្ងៃទី ៣ ធ្នូ ២០០៨ ។ លិខិតនេះមិនត្រូវបានបញ្ចូលទៅក្នុងសំណុំរឿងទេ។

*(Website)មួយ សម្រាប់ផ្តល់ព័ត៌មានទាក់ទងនឹងឯកសារ<u>សារណៈ</u>ទាំងអស់ដែលដាក់ដោយក្រុមមេធាវីការពារក្តីរបស់លោក* ***អៀង សារី*** [6]។" នៅក្នុងលិខិតចុះថ្ងៃទី ២២ ធ្នូ ២០០៨ លោក **តូនី ក្រាញ់** ប្រធានស្តីទីការិយាល័យរដ្ឋបាល បានប្រកាសថា វា "ជាការមិនត្រឹមត្រូវឡើយចំពោះការិយាល័យរដ្ឋបាលដែលត្រូវផ្តល់យោបល់ ឬចាត់វិធានការបន្តទៅទៀតទៅលើ សេចក្តីសម្រេចឯករាជរបស់តុលាការឡើយ[7]។" គ្មានយោបល់ណាមួយនិយាយទាក់ទងនឹងចេតនារបស់មេធាវីការពារក្តីក្នុងការបង្កើតនូវគេហទំព័រនេះឡើយ។

4. ប្រហែលជាមិនបានដឹងអំពីលិខិតរបស់មេធាវីការពារក្តី ដែលលិខិតនោះបានចម្លងជូន ក.ស.ច.ស ដែរនោះ ក.ស.ច.ស បានសរសេរលិខិតមកកាន់ មេធាវីការពារក្តី នៅថ្ងៃទី ២០ មករា ២០០៨ ដោយយោងទៅលើអត្ថបទដែលចុះផ្សាយនៅក្នុងកាសែត **ខេមបូឌៀដេលី** ចុះថ្ងៃទី ១៩ ធ្នូ ២០០៨ ដែលចុះផ្សាយយោងទៅលើចេតនារបស់ មេធាវីការពារក្តី ក្នុងការបង្កើតគេហទំព័រមួយ[8] ។ ជាកិច្ចឆ្លើយតប មេធាវីការពារក្តី បានជូនដំណឹងដោយឆ្លើយតបនឹង ក.ស.ច.ស ថា៖

   "វាមិនចាំបាច់សម្រាប់លោកសហចៅក្រមត្រូវអានសារព័ត៌មាន"*The Cambodia Daily*" ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៨ ដែលនិយាយអំពីគោលបំណងរបស់យើងខ្ញុំ ក្នុងការបង្កើតគេហទំព័រមួយដើម្បីដាក់បង្ហាញនូវឯកសារសាធារណៈដែលដាក់ដោយក្រុមមេធាវីការពារនោះឡើយ ។ គ្រប់ពេលទាំងអស់ យើងខ្ញុំតែងតែខិតខំប្រឹងប្រែងឲ្យមានលក្ខណៈបើកចំហរ និងមានតម្លាភាព ទាក់ទងទៅនឹងគោលបំណងរបស់យើងខ្ញុំទៅលើបញ្ហានេះ។ យើងខ្ញុំបានជូនដំណឹងទៅប្រធានផ្នែកកិច្ចការសាធារណៈ លោកស្រី Helen Jarvis រួចមកហើយ ពីគោលបំណងរបស់យើងខ្ញុំក្នុងការបង្កើតគេហទំព័រមួយ ដែលគោលបំណងនេះត្រូវបានលើកឡើងជាថ្មីទៀតនៅក្នុងលិខិតចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០៨ ផ្ញើរជូនប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាល។

---

[6] *សូមមើល* ឧបសម្ព័ន្ធ ឃ៖ លិខិតទៅកាន់ឯ.ឧ. ស៊ាន វិសុទ្ធ និងឯ.ឧ. Knut ROSANDHAUG និងឯ.ឧ. តូនី ក្រាញ់ ដែលមានចំណងជើងថា "កិច្ចប្រជុំដើម្បីពិភាក្សាអំពីលិខិតរបស់យើងខ្ញុំចុះថ្ងៃទី ៣ ធ្នូ ២០០៨ ទាក់ទងនឹងការជ្រែតជ្រែកមិនត្រឹមត្រូវដោយចៅក្រមនៃបុរេជំនុំជម្រះទៅក្នុងកិច្ចការរដ្ឋបាលរបស់ផ្នែកគ្រប់គ្រងតុលាការ"ចុះថ្ងៃទី១៨ ធ្នូ ២០០៨ (គូសបញ្ជាក់បន្ថែម)។ លិខិតនេះមិនត្រូវបានបញ្ចូលទៅក្នុងសំណុំរឿងទេ។

[7] *សូមមើល* ឧបសម្ព័ន្ធ ង៖លិខិតផ្ញើរមកលោក អាង ឧត្តម និង លោក ម៉ៃខល ខាណាវ៉ាស់ ចុះថ្ងៃទី ២២ ធ្នូ ២០០៨ ។ លិខិតនេះមិនត្រូវបានបញ្ចូលទៅក្នុងសំណុំរឿងទេ។

[8] *ករណី អៀង សារី* សំណុំលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស លិខិតផ្ញើរពី ក.ស.ច.ស មានចំណងជើងថា "ការសម្ងាត់នៃឯកសារក្នុងសំណុំរឿង" ចុះថ្ងៃទី ១៥ មករា ២០០៩ ("លិខិតចុះថ្ងៃទី ១៥ មករា")។

លិខិតនេះក៏ត្រូវបានថតចម្លងលោកសហចៅក្រមផងដែរ។”[9]

5. ដូច្នេះ ដូចដែលអាចមើលឃើញហើយថា មេធាវីការពារក្តី មិនបានបង្កើតគេហទំព័រនេះដោយអាថ៌កំបាំងក្នុងន័យសង្ឃឹមថា គ្មាននរណាម្នាក់មកពី ក.ស.ច.ស អាចដឹងអំពីរឿងនេះឡើយ ។ គេហទំព័រនេះត្រូវបង្កើតឡើងជាចំហរ និងសម្រាប់គោលបំណងដើម្បីធ្វើអោយកិច្ចដំណើរនីតិវិធីតុលាការនៅ អ.វ.ត.ក កាន់តែមានតម្លាភាពឡើងថែមទៀត ។ នេះគឺផ្ទុយគ្នានឹងស្ថានភាពនៃអង្គហេតុនៃទង្វើបើកចំហរ និងមានតម្លាភាពរបស់ មេធាវីការពារក្តី ដែលនាំអោយដីកាស្តីពីការសម្ងាត់ និងទណ្ឌកម្មនានាដែលមានក្នុងដីកានេះ ដាច់ខាតត្រូវតែអោយគេធ្វើការវាយតម្លៃ ។

## III. ភាពទទួលយកបាននៃបណ្តឹងឧទ្ធរណ៍

6. ដីកាស្តីពីការសម្ងាត់ គឺមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងវិធានជាក់លាក់នានាដែលគេសំអាងក្នុងដីកានោះ ។ ប៉ុន្តែ គេបានយោងទៅលើ “វិធានផ្ទៃក្នុង ៥៦(១) និងមាត្រា ២១(៣) នៃកិច្ចព្រមព្រៀង ២០០៣ [10]” ដែលមេធាវីការពារក្តីបានរំលោភបំពាន ដែលការរំលោភបំពាននេះ “អាចត្រូវដាក់ទណ្ឌកម្មតាមវិធាន ៣៥ និង ៣៨ នៃវិធានផ្ទៃក្នុង”[11]។

7. វិធាន ៣៥(៦) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (“វិធាន”) ចែងថា “រាល់សេចក្តីសម្រេចដែលធ្វើឡើងក្រោមវិធាននេះ” អាចត្រូវប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ឬប្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល [12]។ សិទ្ធិប្តឹងឧទ្ធរណ៍នេះត្រូវបានទទួលយកដោយមាត្រា ៧៣(គ) ដែលចែងអំពីយុត្តាធិការរបស់ អង្គបុរេជំនុំជម្រះ ។ វាប្រហែលជាគ្មានអ្វីគួរអោយឆ្ងល់ឡើយថា ដីកាស្តីពីការសម្ងាត់ បង្កើតបានជា “សេចក្តីសម្រេចមួយតាមវិធាននេះ” ហេតុដូច្នេះហើយវាជាកម្មវត្ថុដែលត្រូវប្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរជំនុំជម្រះ ។

## IV. ការកំណត់កាលបរិច្ឆេទដាក់ឯកសារ និង សវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈជាបន្ទាន់

---

[9] *ករណី អៀង សារី* សំណុំលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស លិខិតរបស់មេធាវីការពារក្តី មានចំណងជើងថា “ការសម្ងាត់នៃឯកសារក្នុងសំណុំរឿង” ២០ មករា ២០០៩ ។

[10] ដីកាស្តីពីការសម្ងាត់ កថាខណ្ឌ ១៩ ។

[11] ឯកសារដដែល កថាខណ្ឌ ២០ ។

[12] វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (“វិធាន”) វិធាន ៣៥(៦)

8. មេធាវីការពារក្តី ស្នើសុំអោយដាក់កាលបរិច្ឆេទដើម្បីដាក់ឯកសារជាបន្ទាន់មួយសម្រាប់បណ្តឹងឧទ្ធរណ៍នេះ ជាជម្រើសមួយដែល អង្គបុរេជំនុំជម្រះ បានប្រើប្រាស់ជាញឹកញាប់[13] ។ ថ្វីបើត្រូវបានអនុញ្ញាតអោយអោយដាក់បណ្តឹងឧទ្ធរណ៍ក្នុងរយៈពេល ៣០ថ្ងៃនៃថ្ងៃចេញដីកាស្តីពីការសម្រាត់ ក៏ដោយ ក៏មេធាវីបានបញ្ចប់ និងដាក់ឯកសារបណ្តឹងឧទ្ធរណ៍របស់ខ្លួនតែក្នុងរយៈពេលមួយសប្តាហ៍ប៉ុណ្ណោះគិតពីថ្ងៃជូនដំណឹងអំពីដីកាស្តីពីការសម្រាត់នេះ។ ហេតុដូច្នេះ មេធាវីការពារក្តី សូមស្នើដោយគោរពដល់អង្គបុរេជំនុំជម្រះ សូមអោយបង្គាប់ដល់ភាគីដទៃទៀតនានាដើម្បីដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍នេះក្នុងរយៈពេល ៧ថ្ងៃ គិតពីថ្ងៃទទួលការជូនដំណឹងពីបណ្តឹងឧទ្ធរណ៍នេះ ។ ដោយសន្មតថា កាលបរិច្ឆេទនៃការដាក់ឯកសារនេះត្រូវបានបង្គាប់ដោយ អង្គបុរេជំនុំជម្រះ សារណាលើបណ្តឹងឧទ្ធរណ៍នេះនឹងត្រូវបញ្ចប់នៅត្រឹមថ្ងៃទី ១៧ មីនា ២០០៩ ហើយអាចមានលទ្ធភាពដើម្បីបើកសវនាការដេញដោលផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍នេះនៅថ្ងៃទី ៣ មេសា ២០០៩ ។ គ្រប់ភាគីទាំងអស់អាចនឹងមានពេលទំនេរសម្រាប់សវនាការមួយនៅថ្ងៃនេះ បន្ទាប់ពីបានចំណាយពេលមុននេះមួយថ្ងៃទៅលើសេចក្តីសន្និដ្ឋានផ្ទាល់មាត់នានា ស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបន្តថេរៈវេលាឃុំខ្លួនបណ្តោះអាសន្ន[14]។

9. វិធាន ៧៧(៣) ចែងពីនីតិវិធីចំពោះបណ្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ[15]។ មាត្រានេះចែងថា៖

(ក) ប្រធានអង្គបុរេជំនុំជម្រះ ត្រូវផ្ទៀងផ្ទាត់ថាសំណុំរឿងនោះ មានភាពពេញលេញ និងកំណត់កាលបរិច្ឆេទសវនាការ ។

(ខ) បន្ទាប់ពីបានពិចារណាលើការយល់ឃើញរបស់ភាគី អង្គបុរេជំនុំជម្រះអាចសម្រេចលើបណ្តឹងឧទ្ធរណ៍ ឬ ពាក្យសុំ ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ ។

(គ) ក្រឡាបញ្ជីនៃអង្គបុរេជំនុំជម្រះ ត្រូវជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត ភាគី និងមេធាវីរបស់ពួកគេ អំពីកាលបរិច្ឆេទនៃសវនាការ ឬ ការសម្រេចអំពីដំណើរការនីតិវិធីដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ដែលដាក់ដោយភាគីតែប៉ុណ្ណោះ ។

---

[13] *សូមមើល ករណី អៀង សារី* សំណុំលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ១៧) សេចក្តីណែនាំដល់ភាគីទាក់ទងនឹងសំណើរបស់លោក អៀង សារី សុំអោយកោះអញ្ជើញអ្នកជំនាញវេជ្ជសាស្ត្រសម្រាប់សវនាការដេញដោលផ្ទាល់មាត់ ចុះថ្ងៃទី ១២ កុម្ភៈ ២០០៩ ។

[14] *ករណី អៀង សារី* សំណុំលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ១៧) សេចក្តីសម្រេចជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចផ្ទាល់មាត់នាថ្ងៃទី ២៦ កុម្ភៈ ២០០៩ ទៅលើសំណើសុំដែលដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះនាពេលសវនាការធ្វើឡើងនាថ្ងៃតែមួយ ចុះថ្ងៃទី ២៧ កុម្ភៈ ២០០៩ ។

[15] វិធានផ្ទៃក្នុង (វិ. ២) ធ្វើវិសោធនកម្មនាថ្ងៃទី ៥ កញ្ញា ២០០៨ ។

10. មើលទៅវិធាននេះថា ការសន្មតទុកជាមុនសម្រាប់គ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់ទៅ អង្គបុរេជំនុំជម្រះថានឹងមានសវនាការដេញដោលផ្ទាល់មាត់មួយ ។ អង្គបុរេជំនុំជម្រះ អាចអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួនដើម្បីកំណត់បញ្ហានេះ បើសិនការលើកលែងចំពោះគោលការណ៍នេះត្រូវបានអនុញ្ញាត ។ គ្មានលក្ខណៈវិនិច្ឆ័យណាមួយមានចែងនៅក្នុង វិធានផ្ទៃក្នុងថា នៅពេលណាគេត្រូវងាកចេញពីការសន្មតទុកជាមុនអោយមានសវនាការដេញដោលផ្ទាល់មាត់ឡើយ។ មានបណ្តឹងឧទ្ធរណ៍ជាច្រើនផ្សេងៗគ្នាត្រូវបានចេញសម្រេចតាមរយៈសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ជាទូទៅដោយសារតែមានការព្រមព្រៀងរវាងគូភាគីនានាថា មិនចាំបាច់មានសវនាការដេញដោលផ្ទាល់មាត់ឡើយ[16]។ អង្គបុរេជំនុំជម្រះ បានអនុញ្ញាតតាមសំណើសុំជាបន្តបន្ទាប់ អោយមានសវនាការដេញដោលផ្ទាល់មាត់នៅក្នុងបណ្តឹងឧទ្ធរណ៍មួយ នៅពេលដែលមិនមានការយល់ស្របគ្នារវាងគូភាគី[17]។ លក្ខណៈវិនិច្ឆ័យពីរដែលទំនងជាត្រូវបានប្រើប្រាស់ដើម្បីធ្វើយុត្តិកម្មចំពោះសវនាការដេញដោលផ្ទាល់មាត់គឺ៖ (១) សារៈសំខាន់នៃបញ្ហា និង (២) ការពិតដែលថា មានភាគីមួយបានស្នើសុំអោយមានសវនាការដេញដោលផ្ទាល់មាត់[18] ។

11. ដីកាស្តីពីការសម្ងាត់លើកឡើងនូវបញ្ហាជាសារវ័ន្តនានាដែលប៉ះពាល់មិនត្រឹមតែលើក្រុមមេធាវីការពារក្តីរបស់លោក **អៀង សារី** ប៉ុណ្ណោះទេ ប៉ុន្តែទៅគ្រប់ភាគីនៅចំពោះមុខ អង្គបុរេជំនុំជម្រះ ។ ខណៈដែលប្រឆាំងបន្តិចបន្តួចទៅនឹងមេធាវីការពារក្តី វាក៏ដើរតួដូចជា *ការគំរាមកំហែងដែលមិនប្រែប្រួល និងយូរអង្វែង (sword of Damocles[19])* ដែលនៅតែបន្តលងបន្លាចក្រុមមេធាវីការពារក្តី គំរាមកំហែង

---

[16] *ករណី អៀង សារី* សំណុំលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ១០) សាលដីកាលើសំណើសុំដើម្បីកំណត់ពីបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ស្តីពីការតែងតាំងអ្នកជំនាញដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ ចុះថ្ងៃទី ៧ សីហា ២០០៨ ។

[17] *ករណី ខៀវ សំផន* សំណុំលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ១១) សេចក្តីសម្រេចលើសំណើរបស់លោក ខៀវ សំផន សុំអោយធ្វើសវនាការជាសាធារណៈ ចុះថ្ងៃទី ៤ វិច្ឆិកា ២០០៨ ។ *ករណី អៀង សារី* សំណុំលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ១៧) សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា ដើម្បីកំណត់បណ្តឹងឧទ្ធរណ៍ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរប៉ុណ្ណោះ និងដីកាកំណត់ថ្ងៃសវនាការ ចុះថ្ងៃទី ២៩ មករា ២០០៩ ("សេចក្តីសម្រេចលើសេចក្តីសន្និដ្ឋានលាយលក្ខណ៍អក្សរ")។

[18] សេចក្តីសម្រេចលើសេចក្តីសន្និដ្ឋានលាយលក្ខណ៍អក្សរ កថាខណ្ឌ ៦ ។

[19] ឃ្លានេះមានន័យថា *ស្ថានភាពដែលស្ថិតក្រោមការគំរាមកំហែងដែលមិនប្រែប្រួល និងយូរអង្វែង* ដូចជានៅពេលដែលអ្នកត្រូវបានគេយកដាវមួយមកព្យួរពីលើក្បាលប្រកបដោយគ្រោះថ្នាក់ ហើយចាំតែធ្លាក់ចុះមកនៅពេលណាមួយភ្លាមៗ ។ ពាក្យនេះត្រូវ

បំបាក់នូវលទ្ធភាព និងរារាំងនូវកិច្ចប្រឹងប្រែងរបស់មេធាវីការពារក្ដីក្នុងកិច្ចការពារលោក **អៀង សារី** ។ម្យ៉ាងវិញទៀត អ្វីដែលជាក់ច្បាស់លាក់នោះគឺ មេធាវីការពារក្ដី ប្រាថ្នាអោយមានកិច្ចពិភាក្សាទៅលើបញ្ហាជាសារវន្តនេះនៅក្នុងសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈមួយ ។ សាធារណៈជនទាំងឡាយថែមទាំងអាចទទួលអត្ថប្រយោជន៍ តាមរយៈការសង្កេតការណ៍លើបញ្ហាដ៏មានសារៈសំខាន់ខ្លាំងនេះដែលកំពុងត្រូវបានគេជជែកពិភាក្សានៅក្នុងវិធីមួយដែលមានតម្លាភាពទាំងស្រុង ជាពិសេសនៅពេលបញ្ហាបែបនេះទំនងជាមានឥទ្ធិពលលើ ភាពសម្រេចបាន និងភាពជឿជាក់ទៅលើលទ្ធផលបញ្ចប់កិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ។ ការពិនិត្យមើលជាសាធារណៈនូវកិច្ចដំណើរការនីតិវិធីតុលាការដែលមានតម្លាភាព និងមានយុត្តិធម៌ ដោយការសន្មតថាការពិតវាគឺអ្វីដែលត្រូវបានគេដឹងថាកើតមាននៅ អ.វ.ត.ក នោះ ក្រោយមក អាចជាកេរ្តិ៍ដំណែលដ៏យូរអង្វែងបំផុតមួយរបស់ស្ថាប័ននេះ ។

## V. សេចក្ដីសន្និដ្ឋានឧទ្ធរណ៍

12. មេធាវីការពារក្ដី នឹងបង្ហាញថា៖

A. គោលការណ៍នៃភាពជាសាធារណៈនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការធានាថា មិនមែនរាល់ឯកសារទាំងអស់ដែលបានដាក់នៅចំពោះមុខ ក.ស.ច.ស ត្រូវបានការពារដោយភាពសម្ងាត់នៃកិច្ចស៊ើបសួរនោះឡើយ ។

B. ឯកសារសម្ងាត់ដែលចោទប្រកាន់ណាមួយ ដែលបានដាក់បង្ហាញនៅលើគេហទំព័ររបស់មេធាវីការពារក្ដីគឺគ្រាន់តែជាការសម្ងាត់ដើម្បីការពារសិទ្ធិនានារបស់លោក **អៀង សារី** ជាសិទ្ធិដែលគាត់អាចបោះបង់ចោលបាន ។

C. លិខិតដែលព្រមានក្រុមមេធាវីការពារក្ដីអំពីចេតនាបង្កើតនូវគេហទំព័រផ្ទាល់ខ្លួន និងផ្សព្វផ្សាយនូវការដាក់ឯកសារនានារបស់ខ្លួន គឺថាលិខិតនេះមិនបង្កើតបានជាសេចក្ដីសម្រេច ឬបង្កើតបានជាការព្រមានមួយអនុលោមទៅតាមវិធាន ៣៨(១) ឡើយ និង

---

បាននិយាយដៀមដាមទៅដល់រឿងព្រេងរបស់ Damocles ដែលជាអ្នកអែបអបបំរើអោយស្ដេច Dionysius ទី១ នៃនគរ Syracuse ។ ស្ដេច Dionysius ទី១ ដោយធុញទ្រាន់នឹងពាក្យបញ្ចោរហួសប្រមាណរបស់ Damocles បានអញ្ជើញគាត់អោយចូលរួមពិធីជប់លៀងមួយ ហើយអោយគាត់អង្គុយនៅក្រោមផ្ដែងដាវមួយដែលចងព្យួរនឹងសសៃសក់មួយសសៃ ធ្វើដូច្នេះដើម្បីចង្អុលប្រាប់គាត់អំពីភាពមានគ្រោះថ្នាក់នៃមុខតំណែងរបស់គាត់។

D. ការខកខានរបស់ ក.ស.ច.ស និង អង្គបុរេជំនុំជម្រះ ក្នុងការដាក់ទណ្ឌកម្មទៅលើការរំលោភបំពានដោយខ្លួនឯងជាបន្តបន្ទាប់ ទៅលើកាតព្វកិច្ចរក្សាភាពសម្ងាត់របស់ខ្លួន បង្ហាញនូវការរើសអើងក្នុងប្រព្រឹត្តរវាងមេធាវីការពារក្តី និង អង្គភាពនានារបស់ អ.វ.ត.ក ។

## III. ច្បាប់

### ក. ភាពជាសាធារណៈនៃកិច្ចដំណើរការនីតិវិធី

13. តាមមាត្រា ១១ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស "មនុស្សគ្រប់រូបដែលត្រូវចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ មានសិទ្ធិសន្មតទុកជាមុនថាគ្មានទោសរហូតទាល់តែរកឃើញថាមានទោសទៅតាមច្បាប់នៅក្នុងការជំនុំជម្រះក្តីជាសាធារណៈ ដែលតាមរយៈនេះបុគ្គលនោះមាននូវរាល់កិច្ចធានាចាំបាច់ទាំងអស់សម្រាប់កិច្ចការពារខ្លួនរបស់ខ្លួន"[20]។ មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាអនុវត្តនូវអនុសញ្ញាអន្តរជាតិ នៅកម្រិតថ្នាក់ជាតិថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការប្រជាជាតិ [និង] សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស"[21] ។

14. នៅផ្នែកខាងអឺរុប តុលាការសិទ្ធិមនុស្សអឺរុបបានសន្និដ្ឋានថា ចរិតលក្ខណៈនៃភាពជាសាធារណៈនៃកិច្ចដំណើរការនីតិវិធី "ការពារភាគីវិវាទនានាប្រឆាំងនឹងការគ្រប់គ្រងវិស័យយុត្តិធម៌ដោយអាថ៌កំបាំងដោយគ្មានការឃ្លាំមើលជាសាធារណៈ។ វាក៏ជាមធ្យោបាយមួយផងដែរដែលតាមរយៈនេះ ទំនុកចិត្តទៅលើតុលាការអាចត្រូវបានថែរក្សា។ ដោយអនុវត្តការគ្រប់គ្រងវិស័យយុត្តិធម៌ប្រកបដោយតម្លាភាពជាសាធារណៈ រួមចំណែកដល់ការសម្រេចបានគោលដៅដូចមានចែងក្នុងមាត្រា ៦(១) ដែលហៅថាការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌[22]" ។

---

[20] *សូមមើលផងដែរ* កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយ មាត្រា ១៤(១) អនុសញ្ញាអឺរុបសម្រាប់ការការពារសិទ្ធិមនុស្ស មាត្រា ៦(១) អនុសញ្ញាអាមេរិចស្តីពីសិទ្ធិមនុស្ស ("Pact of San José, Costa Rica") ដែលអនុម័តនៅថ្ងៃទី ២២ វិច្ឆិកា ១៩៦៩ ។ សន្ធិសញ្ញានៃអង្គការនៃបណ្តាប្រទេសអាហ្វ្រិក (O.A.S) លេខ ៣៦ 1144 U.N.T.S. 123 ដែលបានចូលជាធរមាននៅថ្ងៃទី ១៨ កក្កដា ១៩៧៨ ត្រូវបានបោះពុម្ពឡើងវិញនៅក្នុងឯកសារគោលទាក់ទងនឹងសិទ្ធិមនុស្សនៅប្រព័ន្ធអន្តរអាមេរិច OEA/Ser.L.V/II.82 doc.6 rev.1 at 25 (1992) មាត្រា ៨(៥) ។

[21] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៣១ ត្រូវបានអនុម័តដោយសភាធម្មនុញ្ញនៅភ្នំពេញកាលពីថ្ងៃទី ២១ កញ្ញា ១៩៩៣ នៅសម័យប្រជុំពេញអង្គលើកទី ២ របស់ខ្លួន និងត្រូវបានអនុម័តដោយរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី ៤ មីនា ១៩៩៩ នាសម័យប្រជុំពេញអង្គលើកទី២ របស់ខ្លួន ។

[22] តុលាការសិទ្ធិមនុស្សអឺរុប ECHR , *រឿងក្តី Werner តតាំងនឹងប្រទេសអូទ្រីស. Austria*, សាលក្រមចុះថ្ងៃទី ២៤ វិច្ឆិកា ១៩៩៧ កថាខណ្ឌ ៤៥ គូសបញ្ជាក់បន្ថែម។

15. អតីតអនុប្រធាន និង ជាចៅក្រមសាលាឧទ្ធរណ៍នៃ ICTY ចៅក្រម Florence Mumba បានគូស បញ្ជាក់ថា ខណៈតម្រូវការឱ្យមានការលើកលែងដែលមានកម្រិតចំពោះសិទ្ធិទទួលបានការជំនុំជម្រះក្តី ជាសាធារណៈ, សវនាការជាសាធារណៈ "ដើរតួយ៉ាងសំខាន់ក្នុងគោលបំណងអប់រំ តាមរយៈការជួយ ដល់ប្រជាជនឱ្យយល់ដឹងថា តើគេអនុវត្តច្បាប់យ៉ាងដូចម្តេចចំពោះអង្គហេតុនានាដែលបង្កើតបានជា បទឧក្រិដ្ឋ និងបំពេញតួនាទីជាអ្នកត្រួតពិនិត្យលើ "សវនាការប្រឌិត" ("framed" trials) និង ផ្តល់ អោយប្រជាជននូវឱកាសធ្វើសំណូមពរ កែប្រែច្បាប់ ឬ ប្រព័ន្ធយុត្តិធម៌"[23] ។ ស្រដៀងគ្នានេះ អង្គជំនុំ ជម្រះនៅក្នុងរឿងក្តីរវាងរដ្ឋអាជ្ញាប្រឆាំងនឹង Delalic យល់ឃើញដូចខាងក្រោមថា៖

៣៣. វាមានសារៈសំខាន់ក្នុងការកត់សំគាល់ថា អង្គជំនុំជម្រះសាលាដំបូងមិនអាចបដិសេធន៍ដោយគ្មាន មូលហេតុសមស្របនូវសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះក្តីជាសាធារណៈ ដូចបាន ចែងនៅក្នុងមាត្រា ២០(៤)និង ២១(២) នោះឡើយ។ វិធាន ៧៥(ក) ដែលបានអនុម័តស្របតាមមាត្រា ២២ ចែងថា:

> *តាមគំនិតផ្តួចផ្តើមរបស់ខ្លួន* ឬ តាមសំណើរបស់ភាគីណាមួយក៏បាន ឬ តាមសំណើរបស់ ជនរងគ្រោះ ឬ សំណើរបស់អង្គភាពជនរងគ្រោះ និង សាក្សីពាក់ព័ន្ធ ចៅក្រម ឬ អង្គជំនុំ ជម្រះអាចបង្គាប់នូវវិធានការការពារសម្រាប់ភាពឯកជន និងសម្រាប់ការពារជនរងគ្រោះ និង សាក្សី ឱ្យតែវិធានការនោះស្របតាមសិទ្ធិរបស់ជនត្រូវចោទ ។

ហេតុដូច្នេះ វិធានការដែលបង្កើតឡើងស្របតាមអំណាចនៃមាត្រា ២២ ត្រូវតែស្របជាមួយសិទ្ធិរបស់ ជនជាប់ចោទ ។ លក្ខន្តិកៈរបស់តុលាការអន្តរជាតិសង្កត់ធ្ងន់ទៅលើការជំនុំជម្រះក្តីដែលមាន ចរិតជា សាធារណៈ ដែលជាលក្ខណៈពិសេសមួយនៃដំណើរការនីតិវិធី (មាត្រា ២០(៤) និង ២១(២)។

៣៤. ផលប្រយោជន៍ដ៏ចម្បងនៃការអនុញ្ញាតិឱ្យសាធារណជន និង សារព័ត៌មានចូលរួមសវនាការ គឺថា វត្តមានរបស់ពួកគេបានចូលរួមចំណែក ដើម្បីធានាធានាឱ្យមានការជំនុំជម្រះក្តីដោយយុត្តិធម៌។ ក្នុងករណី Pretto & Ors ប្រឆាំងនឹងអ៊ីតាលី (លេខស៊េរី A No. 71 (1984) 6 EHRR 182) តុលាការសិទ្ធិអឺរ៉ុប (ECHR) បានថ្លែងជាសារណៈថា "ភាពជាសាធារណៈ គឺត្រូវបានគេយល់ឃើញថា ជាការធានាឱ្យមានការ ជំនុំជម្រះក្តីដោយយុត្តិធម៌។ វាផ្តល់ការការពារប្រឆាំងនឹងការសម្រេចតាមទំនើងចិត្ត និង កសាងជំនឿទុក

---

[23] លោកចៅក្រម Florence Mumba,បានពោលថា ការធានាឱ្យមានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលស្របពេលជាមួយគ្នា នេះ ត្រូវការពារជនរងគ្រោះ និង សាក្សី ធ្វើឱ្យមានតុល្យភាពនៃផលប្រយោជន៍ ។ លោកបានពោលដូច្នេះនៅក្នុងការពង្រាង សាកល្បងនៃវិធានស្តីពីនីតិវិធី និង ភស្តុតាងរបស់ ICTY ក្នុងការផ្តល់កត្តិយស់ដល់ Gabrielle Kirk McDonald (Richard May et al. eds., 2001), ទំព័រ 359, 365 ។

ចិត្ត តាមរយៈការអនុញ្ញាតិឲ្យមហាជនមើលឃើញយុត្តិធម៍ត្រូវបានធ្វើឡើងដោយវិធីត្រឹមត្រូវ និង មានសមធម៍"។ ហេតុដូច្នេះ <u>សវនាការជាសាធារណៈ គឺសំខាន់សម្រាប់ជាប្រយោជន៏របស់ជនជាប់ចោទ ហើយមិនចាំបាច់សម្រាប់ជាប្រយោជន៏សាធារណៈនោះទេ</u>។ ខាងក្រោមគឺជាសុភាសិតរបស់ចៅក្រមជាន់ខ្ពស់ Warren នៅក្នុងរឿងក្តី Estes ប្រឆាំងនឹងរដ្ឋ Texas ដែលរឿងក្តីនេះ ត្រូវបានសម្រេចដោយតុលាការកំពូលសហរដ្ឋអាមេរិក ដែលគាំទ្រដល់ទស្សនៈនេះ[24] ៖

> មិនត្រូវស្រពិចស្រពិលនោះទេចំពោះការណ៍ដែលថា វាមានផលប្រយោជន៏សង្គមដ៏ខ្លាំងនៅក្នុងការជំនុំជម្រះក្តីជាសាធារណៈ។ ភាពបើកចំហរនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការ អាចកែលំអគុណភាពនៃសក្ខីកម្ម លួងលោមសាក្សីដែលមិនស្គាល់ព្រមផ្តល់សក្ខីកម្មពាក់ព័ន្ធ ញ៉ាំងឲ្យអ្នកចូលរួមការកាត់សេចក្តីទាំងអស់ទាំងអស់បំពេញតួនាទីរបស់ខ្លួនប្រកបដោយឆន្ទៈ 381 U.S. 532 at 583 (1965).

16. បើក្រឡេកមើលប្រព័ន្ធច្បាប់របស់ប្រទេសបារាំងវិញ ដែលស្រដៀងនឹងប្រព័ន្ធច្បាប់ដែលវិធានផ្ទៃក្នុងធ្វើជាមូលដ្ឋាននៅ អ.វ.ត.ក[25] "សញ្ញាណនៃគោលការណ៍សមភាពនៃមធ្យោបាយតទល់ក្តីគ្នា និង សញ្ញាណនៃការសួរដេញដោលបើកចំហ ត្រូវបានគេយកមកសំអាងកាន់តែច្រើនឡើងថាជាការធានាដល់ភាពត្រឹមត្រូវ និង បានដាក់បញ្ចូលទៅក្នុងដំណាក់កាលនីតិវិធីផ្សេងៗគ្នានៃនីតិវិធីព្រហ្មទណ្ឌ"នៅក្នុងប្រព័ន្ធច្បាប់បារាំង[26]។ ឧទាហរណ៏សំខាន់មួយ គឺការណែនាំនូវការជំនុំជម្រះជាសាធារណៈនៅចំពោះមុខ*សភាស៊ើបសួរ* (*chambre d'instruction*) តាមសំណើរបស់ជនត្រូវចោទ លុះត្រាតែវាគំរាមកំហែងដល់សន្តិសុខរបស់ស្ថាប័ន ឬ ដល់តតីយជន[27]។

---

[24] ករណីរវាងរដ្ឋអាជ្ញាប្រឆាំងនឹង Delalic សេចក្តីសម្រេចលើពាក្យសុំរបស់អយ្យការ ឬ វិធានការការពារសាក្សីដែលមានរហ្សនាមពីអក្សរ "B" រហូតដល់ "M ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ១៩៩៧ កថាខណ្ឌ ៣៣និង៣៤ ។ គូសបញ្ជាក់បន្ថែម។

[25] *ករណី អៀង សារី* សំណុំលេខ 00២/១៩-0៩-២00៧-អវតក/កសចស(អបជ១២) សាលដីកាលើបណ្តឹងឧទ្ធរណ៏របស់ អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើសិទ្ធិបកប្រែ និង កាតព្វកិច្ចរបស់ភាគី ចុះថ្ងៃទី២0 ខែកុម្ភៈ ឆ្នាំ២00៨ កថាខណ្ឌ ២0។

[26] Jacqueline Hodgson ជនសង្ស័យ, ចុងចោទ និង ជនរងគ្រោះនៅក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌបារាំង 51 Int'l & Comp. L.Q. 781, 785 (2002) ។

[27] នៅក្នុងករណី *Reinhardt and Slimane-Ka d* ប្រឆាំងនឹងប្រទេសបារាំង តុលាការសិទ្ធិមនុស្សអឺរ៉ុបសម្រេចថា ទស្សនៈមួយចំនួននៃនីតិវិធីបណ្តឹងឧទ្ធរណ៏នៅចំពោះមុខតុលាការ the Court of Cassation និង ក្រុមប្រឹក្សារដ្ឋ មិនផ្តល់ឲ្យគូវិវាទនូវសិទ្ធិ "ទទួលបានសវនាការជាសាធារណៈ" ដូចដែលបានធានាដោយមាត្រា ៦(១) នៃអនុសញ្ញាអឺរ៉ុប ។ Martin A. Rogoff

17. មេធាវីការពារក្តី ទទួលស្គាល់យ៉ាងពេញទំហឹង និង បានព្យាយាមឥតងាករេដើម្បីគោរពទៅតាមវិធាន ផ្ទៃក្នុង ៥៦(១) ដែលផ្តល់ចែងថា *"ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ភាគី ការស៊ើបសួរមិនត្រូវធ្វើឡើងជាសាធារណៈឡើយ។ បុគ្គលទាំងអស់ដែលចូលរួមក្នុងការស៊ើបសួរត្រូវរក្សាអោយបាននូវការសម្ងាត់"*[28]។ លើសពីនេះ មេធាវីការពារក្តី ទទួលស្គាល់ថា មាត្រា ១២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា ("ក្រមនីតិវិធីព្រហ្មទណ្ឌ") ដែលចែងថា "ការស៊ើបសួរត្រូវតែជាការសម្ងាត់" ធ្វើការបន្ទរនូវច្បាប់នៃការសម្ងាត់ ។ ប៉ុន្តែវាគួរអោយធ្វើការគូសបញ្ជាក់ថា បទបញ្ញត្តិទានាជាបន្តបន្ទាប់នៃវិធានផ្ទៃក្នុង និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ដោយមិនត្រូវមិនយកចិត្តទុកដាក់ឡើយ មានភាពព្រលំគ្នាចំពោះការវាយតម្លៃដែលច្បាស់លាស់ដោយសន្មតទៅលើការសម្ងាត់។

ក. ទីមួយ មាត្រា ១២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងបន្ថែមទៀតថា "ការសម្ងាត់វិជ្ជាជីវៈមិនអាចជាឧបសគ្គដល់ការប្រើសិទ្ធិនៃការការពារខ្លួនឡើយ"[29]។ នេះគឺបង្ហាញយ៉ាងច្បាស់អំពីការកំណត់ព្រំដែនចំពោះគោលការណ៍នៃភាពសម្ងាត់ដោយសន្មត។

ខ. ទីពីរ ទាំង អង្គបុរេជំនុំជម្រះ ទាំង ក.ស.ច.ស ត្រូវបានអនុញ្ញាតអោយផ្សព្វផ្សាយនូវកិច្ចដំណើរការនីតិវិធីខ្លះៗ ដែលបង្កើតបានជាផ្នែកមួយនៃកិច្ចស៊ើបសួរ។ តាមវិធាន ៥៦(២) ក.ស.ច.ស អាច "ផ្តល់នូវព័ត៌មានពាក់ព័ន្ធទៅនឹងសំណុំរឿងដែលកំពុងស្ថិតនៅក្នុងកិច្ចស៊ើបសួរ ប្រសិនបើយល់ឃើញថាជាការចាំបាច់ ដើម្បីធ្វើអោយសាធារណៈជនបានដឹងអំពីកិច្ចដំណើរការនីតិវិធី ឬដើម្បីកែតម្រូវព័ត៌មានមិនពិត ឬព័ត៌មាននាំអោយមានការភ័ន្តច្រលំ"[30]។ ទន្ទឹមគ្នានេះ អង្គបុរេជំនុំជម្រះ មានកាតព្វកិច្ចតាមវិធាន ៧៨ <u>ត្រូវបោះពុម្ពផ្សាយទាំងស្រុង</u> "រាល់សេចក្តីសម្រេចដែលមានសំលេងគាំទ្រគ្រប់គ្រាន់ និងរាល់សេចក្តីសម្រេចដែលមិនមានសម្លេងគ្រប់គ្រាន់ រួមទាំងមតិជំទាស់ផង [...] លើកលែងតែអង្គបុរេជំនុំជម្រះសម្រេចថា ការបោះពុម្ពផ្សាយនោះអាចប៉ះពាល់ ដល់ផលប្រយោជន៍នៃការអង្កេតបឋម ឬការស៊ើបសួរ"[31]។ នេះគឺបញ្ច្រាសគ្នានឹងការសន្មតទុកជាមុនអំពីភាព

---

ការអនុវត្តសន្ធិសញ្ញា និង សេចក្តីសម្រេចរបស់តុលាការអន្តរជាតិនៅសហរដ្ឋអាមេរិក និង បារាំង Maine Law Review 2006 Symposium, 58 Me. L. Rev. 406, 458 (2006) ។

[28] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ១២១ ។

[29] អត្ថបទខាងលើដដែល ។

[30] វិធាន ៥៦(២) ។

[31] វិធាន ៧៨ ។

សម្ងាត់នៃការស៊ើបសួរ នៅពេលដែលរាល់សេចក្តីសម្រេចទាំងអស់របស់ អង្គបុរេជំនុំជម្រះ គឺជាផ្នែកមួយនៃសំណុំរឿង ។

គ. ទីបី មាត្រា ៣.១២ នៃសេចក្តីណែនាំអនុវត្តសម្រាប់ការដាក់ឯកសារ ខណៈដែលព្យាយាមរក្សានូវការសម្ងាត់ដែលចោទប្រកាន់នៃការស៊ើបសួរ ចែងថា “ភាគីដែលដាក់ឯកសារអាចបង្ហាញពីសំណូមពររបស់ខ្លួនដើម្បីដាក់ឯកសារនោះ ត្រូវគេកំណត់អត្តបទ “សាធារណៈ” “សំងាត់” ឬ “បិទស្លាកបោះត្រា””[32]។ ការពិតគឺថា ភាគីនីមួយៗមានជម្រើសនេះដើម្បីបង្ហាញថា មានលទ្ធភាពដែលថា ការដាក់ឯកសារមួយចំនួនដែលមិនទាក់ទងនឹងខ្លឹមសារនៃការស៊ើបសួរ ដាក់ដោយគូភាគី អាចត្រូវបានគេផ្សព្វផ្សាយ។ ការពិត បើក្រលេកមួយភ្លែតមើលគេហទំព័រផ្លូវការរបស់ អ.វ.ត.ក ឃើញថា មានសេចក្តីសន្និដ្ឋានមួយចំនួនដែលធ្វើឡើងដោយភាគីត្រូវបានផ្សព្វផ្សាយ និងដាក់ជាសាធារណៈលើអ៊ីនធើណេត[33]។ ថ្វីបើ ក.ស.ច.ស បានផ្សព្វផ្សាយនូវសេចក្តីសម្រេចរបស់ខ្លួនមានចំនួនតិចជាងគេ បើប្រៀបធៀបទៅភាគីដទៃទៀត យ៉ាងណាក៏ ក.ស.ច.ស បានផ្សព្វផ្សាយចំនួន ២២ ឯកសារ ដែរ គិតមកដល់ថ្ងៃទី ៣ មីនា ២០០៨ ។

## ខ. កាតព្វកិច្ចនៃក្រមសីលធម៌របស់មេធាវី

18. បទបញ្ញត្តិទាក់ទងនឹងកាតព្វកិច្ចរបស់មេធាវីការពារក្តីនៅចំពោះមុខ អ.វ.ត.ក មានចែងនៅក្នុងវិធាន ៣៥ និង ៣៨ ។ នៅក្នុងផ្នែកដែលទាក់ទង វិធានផ្ទៃក្នុងចែងថា៖

**វិធាន ៣៥៖ ការជ្រៀតជ្រែកចូលក្នុងកិច្ចរដ្ឋបាលរបស់អង្គជំនុំជម្រះ**

១. អង្គជំនុំជម្រះវិសាមញ្ញអាចដាក់ទណ្ឌកម្ម ឬបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ចនូវជនណាម្នាក់ដែលជ្រៀតជ្រែកដោយចេតនាពិតប្រាកដ ក្នុងកិច្ចការរដ្ឋបាលរបស់អង្គជំនុំជម្រះ រួមទាំងបុគ្គលដែលមានចែងដូចខាងក្រោម៖

ក) ផ្សាយចេញព័ត៌មានសម្ងាត់ ដោយរំលោភទៅនឹងដីការបស់សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ។

[...]

៥. ប្រសិនបើរកឃើញថា មេធាវីណាម្នាក់បានប្រព្រឹត្តនូវអំពើណាមួយដូចមានចែងក្នុងអនុវិធាន១ ខាងលើ

[32] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ មាត្រា ៣.១២ ។

[33] *សូមមើល* ឧបសម្ព័ន្ធ ច៖ បញ្ជីរាយការដាក់ឯកសារដែលដាក់ជូនដោយអង្គបុរេជំនុំជម្រះ ក.ស.ច.ស សហព្រះរាជអាជ្ញា ឬ មេធាវីការពារក្តី ដែលបានស្រង់យកចេញមកពី គេហទំព័រផ្លូវការរបស់ អ.វ.ត.ក នៅថ្ងៃទី ១០ មីនា ២០០៨ ។

សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះដែលរកឃើញកំហុសនោះ អាចកំណត់ថាការប្រព្រឹត្តថាអំពើនេះគឺជាកំហុសវិជ្ជាជីវៈរបស់មេធាវី ដូចមានចែងក្នុងវិធាន ៣៨ ។

៦. រាល់សេចក្តីសម្រេចដែលធ្វើឡើងក្រោមវិធាននេះ អាចត្រូវប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ ឬប្តឹងសាទុក្ខទៅអង្គជំនុំជម្រះតុលាការកំពូល អាស្រ័យទៅតាមករណីនីមួយៗ ។ ការជូនដំណឹងពីបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខអាចធ្វើឡើងក្នុងរយៈពេល ១៥ថ្ងៃ ក្រោយពេលទទួលដំណឹងអំពីសេចក្តីសម្រេចដល់អ្នកពាក់ព័ន្ធ ។

**វិធាន ៣៨៖ កំហុសវិជ្ជាជីវៈរបស់មេធាវី**

១. សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ ក្រោយពេលព្រមាន អាចដាក់ទណ្ឌកម្ម ឬបដិសេធក្នុងការចូលរួមសវនាការចំពោះមេធាវីណាមួយ ប្រសិនបើយល់ឃើញថា ការប្រព្រឹត្តរបស់មេធាវីរូបនោះជាការប្រមាថមើលងាយ រាំងស្ទះដល់កិច្ចដំណើរការនីតិវិធី រំលោភទៅលើរឿងក្តី ឬទៅនឹងមាត្រា ២១(៣) នៃកិច្ចព្រមព្រៀង ។[34]

19. មានទំនាស់រវាងវិធានផ្ទៃក្នុងទាំងនេះ ទៅនឹងមាត្រា ២១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជជាតិ និងរដ្ឋាភិបាលកម្ពុជាក្នុងការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ[35] ។ តាមមាត្រា ២១(១) នៃកិច្ចព្រមព្រៀងនេះ "រាជរដ្ឋាភិបាលមិនត្រូវដាក់មេធាវីរបស់ជនសង្ស័យ ឬជនជាប់ចោទដែលត្រូវទទួលស្គាល់ដោយអង្គជំនុំជម្រះវិសាមញ្ញអោយស្ថិតនៅក្រោមវិធានការណាមួយ ដែលអាចប៉ះពាល់ដល់ការបំពេញតួនាទីដោយសេរី និងឯករាជ្យរបស់ពួកគេនៅក្រោមកិច្ចព្រមព្រៀងនេះ" [36]។ លើសពីនេះ មាត្រា ២១(២) ធានាថា មេធាវីនេះត្រូវទទួលបាន "អភ័យឯកសិទ្ធិលើយុត្តាធិការព្រហ្មទណ្ឌ ឬរដ្ឋប្បវេណីទាក់ទងនឹងពាក្យសម្តី និយាយឬសរសេរ និងសកម្មភាពដែលពួកគេបានបំពេញនៅក្នុងតួនាទីផ្លូវការជាមេធាវី[37]។" ជាក់ច្បាស់ជាងនេះទៅទៀត មាត្រា ២៤ នៃក្រមសីលធម៌របស់មេធាវីកម្ពុជាចែងថា "មេធាវីមានសិទ្ធិបញ្ចេញមតិទាំងអស់ដែលខ្លួនគិតថាសមស្របដល់ប្រយោជន៍របស់កូនក្តីរបស់ខ្លួន" [38] ។

[34] វិធានផ្ទៃក្នុង (វិ.២) លើកលែងមាត្រា ៣៥ និង ២៨ ត្រូវបានធ្វើវិសោធនកម្មកាលពីថ្ងៃទី ៥ កញ្ញា ២០០៨ (គូសបញ្ជាក់បន្ថែម) ។

[35] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ៦ មិថុនា ២០០៣ ("កិច្ចព្រមព្រៀង")។

[36] អត្ថដដែល មាត្រា ២១(១) (គូសបញ្ជាក់បន្ថែម) ។

[37] អត្ថបទដដែល មាត្រា ២១(២)(គ) ។

[38] ក្រមសីលធម៌សំរាប់មេធាវីចុះបញ្ជីនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ២៤ ចុះថ្ងៃទី ១៥ វិច្ឆិកា ១៩៩៥ ។

### គ. ភាតព្វកិច្ចនៅវិញទៅមកចំពោះការសម្ងាត់របស់ស្ថាប័ននានាផ្សេងទៀតរបស់ អ.វ.ត.ក

20. មកត្រឹមកម្រិតដែលថា មានកាតព្វកិច្ចនៃការសម្ងាត់ដែលគ្មានមន្ទិល មានតម្លាភាព និងជាក់ច្បាស់នៅក្នុងការស៊ើបសួរ វាអនុវត្តដោយគ្មានបែងចែកចំពោះ "ព្រះរាជអាជ្ញា ចៅក្រម មេធាវី ក្រឡាបញ្ជី មន្ត្រីនគរបាលយុត្តិធម៌ និងកងរាជអាវុធហត្ថ មន្ត្រីរាជការស៊ីវិល អ្នកជំនាញ អ្នកប្រែផ្ទាល់មាត់ ឬសរសេរ វេជ្ជបណ្ឌិត"[39] ។ លើសពីនេះទៅទៀត ក្រោមវិធាន ២១(១)(ខ) "ចំពោះបុគ្គលទាំងឡាយដែលរកឃើញថា ស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នា និងត្រូវបានចោទប្រកាន់ចំពោះបទល្មើសដូចគ្នា ត្រូវយកវិធានដូចគ្នាមកអនុវត្ត"[40]។ កាតព្វកិច្ចនៃការប្រព្រឹត្តដោយស្មើភាពគ្នានេះ អនុវត្តមិនត្រឹមតែជនទាំងឡាយដែលប្រឈមនឹងការចោទប្រកាន់ដោយ អ.វ.ត.ក ចំពោះឧក្រិដ្ឋកម្មដែលចោទប្រកាន់ថាបានកើតមានឡើងនាអំឡុងឆ្នាំ ១៩៧៥-៧៩ ប៉ុណ្ណោះទេ តែក៏ទៅលើជនទាំងឡាយដែលប្រឈមនឹងវិធានការវិន័យ ឬរដ្ឋបាលចំពោះសកម្មភាពរបស់ពួកគេនៅ អ.វ.ត.ក ។

21. ទាក់ទងនឹងសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ដើម្បីផ្តល់នូវព័ត៌មានជាសាធារណៈស្តីពីការស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាច "ផ្តល់ការអនុញ្ញាតដោយរួមគ្នាដល់សារព័ត៌មាន ឬអ្នកដទៃទៀតដែលមិនមែនជាភាគី អោយចូលរួមដោយមានកម្រិតនៅក្នុងកិច្ចស៊ើបសួរ ដោយការចូលរួមនេះត្រូវស្ថិតនៅក្រោមការពិនិត្យដ៏តឹងរឹងរបស់ខ្លួន *និង*បន្ទាប់ពីបានសួរយោបល់របស់ភាគីនៅក្នុងកិច្ចដំណើរការនីតិវិធីនេះ"[41]។

## VI. ឧត្តរីករណ៍

### ក.គោលការណ៍នៃការផ្សព្វផ្សាយដំណើរការនីតិវិធីតុលាការដើម្បីធានាថា មិនមែនរាល់ឯកសារដែលដាក់នៅ ក.ស.ច.ស ត្រូវបានការពារដោយការសម្ងាត់នៃកិច្ចស៊ើបសួរនោះឡើយ

22. គោលការណ៍នៅក្នុងវិធាន ៥៦(១) ចែងថា "កិច្ចស៊ើបសួរមិនត្រូវធ្វើឡើងជាសាធារណៈឡើយ" ជាកម្មវត្ថុដល់ការលើកលែងជាច្រើនដែលថា ដើម្បីជាមូលដ្ឋានដល់ការដាក់ទណ្ឌកម្មដោយផ្អែកលើគោលការណ៍ស្រពិចស្រពិលនេះ គឺមិនខុសពីការអនុវត្តអំណាចតាមទំនើងចិត្ត ជាជាងការអនុវត្តច្បាប់ប្រកបដោយគតិបណ្ឌិតនោះ។ ជាការពិត តាមការពិពណ៌នានៅក្នុងសេចក្តីថ្លែងការណ៍រួមរបស់

---

[39] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ១២១ ។

[40] វិធាន ៥៦(២)(ខ) (គូសបញ្ជាក់បន្ថែម) ។

[41] វិធាន ៥៦(២)(ខ) (គូសបញ្ជាក់បន្ថែម) ។

អង្គការក្រៅរដ្ឋាភិបាល បន្ទាប់ពីកិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក "ការអនុវត្តបច្ចុប្បន្ននៅពេលណាដែលការសន្ទត់ជាមុន គាំទ្រដល់ការសម្ងាត់ ហើយមានតែចៅក្រមទេអាចសម្រេចថា ព័ត៌មានអ្វីខ្លះត្រូវបង្ហាញ គឺតាមទំនើងចិត្ត"[42] ។

23. តាមពិត ក.ស.ច.ស តែងតែផ្សព្វផ្សាយនូវដីកាសម្រេចរបស់ខ្លួនដែលពាក់ព័ន្ធជាមួយការស៊ើបសួរលើគេហទំព័ររបស់ អ.វ.ត.ក ដូចជាដីកាសម្រេចថ្មីៗនេះស្តីពីការបន្តថេរវេលានៃការឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទទាំងអស់នៅក្នុងសំណុំរឿងលេខ ០០២[43]។ ឥឡូវនេះ ក.ស.ច.ស យល់ព្រមយ៉ាងយឺតយ៉ាវថា ខ្លួនត្រូវតែតែប្រតិបត្តិឱ្យកាន់បើកចំហរ និង មានតម្លាភាពច្រើន: "...*ដើម្បីធានាបាននូវប្រសិទ្ធិភាពនៃគោលការណ៍ទាំងអស់ខាងលើ សហចៅក្រមស៊ើបអង្កេតនឹងធ្វើការផ្សព្វផ្សាយឱ្យបានច្រើនជាងមុនអំពីសកម្មភាពនានារបស់ខ្លួន និងធ្វើការបោះផ្សាយឯកសារដែលទាក់ទងនឹងកិច្ចស៊ើបសួរក្នុងចំនួនច្រើនជាងមុនផងដែរ*"[44] ។ អ្វីដែលប្លែកនោះ ហាក់ដូចជាពុំមានអ្វីដើម្បីញែកឱ្យដាច់ពីគ្នានូវសេចក្តីសម្រេចដែលបានផ្សព្វផ្សាយ ពីសំណើទាំងឡាយដែលត្រូវបានសំអាង វៀរលើកលែងតែថាដីកាសម្រេចរបស់ ក.ស.ច.ស ត្រូវបានផ្សព្វផ្សាយ ដែលសំណើនានា ដែលមិនមានសារជាតិសម្ងាត់មិនត្រូវបានផ្សព្វផ្សាយទៅវិញ។ ភាពមិន ស៊ីគ្នានេះកាន់តែមិនអាចស្ថិតស្ថេរបាន ប្រសិនបើមិនអាចទទួលយកបាន នៅពេលសេចក្តីសម្រេចរបស់ ក.ស.ច.ស ត្រូវបានប្តឹងឧទ្ធរណ៍ ហើយបណ្តឹងឧទ្ធរណ៍គឺធ្វើឡើងជាសាធារណៈ ខណៈដែលសំណៅ ដើមទៅចំពោះមុខ ក.ស.ច.ស មិនបានធ្វើជាសាធារណៈទៅវិញ បើទោះបីខ្លឹមសាររបស់វាមានព័ត៌មានដូចគ្នាដ៏ដោយ[45]។ ការសើចអំចកទៅលើវា គឺកំពុងតែវិលវល់។

---

[42] សេចក្តីថ្លែងការណ៍របស់អង្គការក្រៅរដ្ឋាភិបាល ។

[43] សូមមើលឧបសម្ព័ន្ធ ច ។

[44] សូមមើលសេចក្តីប្រកាសព័ត៌មានរបស់ ក.ស.ច.ស ចេញផ្សាយនៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០០៩ ។

[45] សូមមើលករណី អៀង សារី សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស សំណើសុំព័ត៌មានទាក់ទងនឹងភាពលំអៀងឃើញច្បាស់ក្រឡែក និង ទំនាស់ផលប្រយោជន៍យ៉ាងខ្លាំងនៃមន្ត្រីផ្នែកច្បាប់របស់ ក.ស.ច.ស លោក David Boyle ចុះថ្ងៃទី៤ ខែមិនា ឆ្នាំ២០០៨ ដែលដាក់ជាសាធារណៈដោយមេធាវីការពារ តែតាមការពិតសំណើនេះ គឺជាសំណើសម្ងាត់ផ្ទុយទៅវិញ បណ្តឹងឧទ្ធរណ៍ដោយមេធាវីការពារប្រឆាំងនឹងការបដិសេធសំណើនេះដែលមានព័ត៌មានដូចគ្នា គឺត្រូវបានធ្វើជាសាធារណៈ ហើយត្រូវបានផ្សព្វផ្សាយលើគេហទំព័ររបស់ អ.វ.ត.ក។ ករណី អៀង សារី សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស បណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់ ក.ស.ច.ស លើភាពលំអៀងឃើញច្បាស់ក្រឡែក និង ទំនាស់ផលប្រយោជន៍យ៉ាងខ្លាំងនៃមន្ត្រីផ្នែកច្បាប់របស់ ក.ស.ច.ស លោក David Boyle ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៨ ។

24. រួមជាមួយភាពមិនប្រក្រតីនេះ គឺនិយមន័យនៃពាក្យ "សាធារណៈ" ដែលសាំញាំ និងដ៏ភាន់ច្រឡំដែលបង្កើតឡើងដោយអ្នកនិពន្ធ Franz Kafkaesque[46] ដែលត្រូវបានប្រើដោយ ក.ស.ច.ស ។ ចាប់តាំងពីពេលចេញដីកាសម្រេចលើភាពសម្ងាត់មក មេធាវីការពារបានស្វែងរកយ៉ាងយកចិត្តទុកនូវការណែនាំពី ក.ស.ច.ស ទាក់ទងនឹងការដាក់ឯកសារមួយណាដែលត្រូវចាត់ជាសម្ងាត់ ដែលត្រូវដកចេញពីការផ្សព្វផ្សាយ ហើយថាតើឯកសារមួយណាត្រូវផ្សព្វផ្សាយជាសាធារណៈ ដែលអាចបន្តផ្សព្វផ្សាយនៅលើគេហទំព័ររបស់មេធាវីការពារទៅទៀត។ អនុលោមតាម ក.ស.ច.ស "ដើម្បីគោរពតាមដីកាបង្គាប់ អ្នកត្រូវដកជាបន្ទាន់នូវឯកសារទាំងឡាយណានៅក្នុងសំណុំរឿង ដែលមិនបានផ្សព្វផ្សាយនៅលើគេហទំព័ររបស់ អ.វ.ត.ក" [47]។ ដូច្នេះ វាពិតណាស់ថា ផ្នែកកិច្ចការសារធារណៈរបស់ អ.វ.ត.ក ជាអាជ្ញាកណ្តាលចុងក្រោយនៃអ្វីដែលចាត់ទុកថាជាការសម្ងាត់ ដោយសារតែផ្នែកនេះ នឹងសម្រេចថាតើឯកសារមួយណាត្រូវដាក់បង្ហាញនៅលើគេហទំព័រនោះ។

25. ថ្វីបើអង្គហេតុដែលថា ឯកសារដែលមិនមានអ្វីទាំងអស់ ប៉ុន្តែ មានព័ត៌មានសំរាប់សាធារណៈ ត្រូវដាក់ជាសាធារណៈ និង ត្រូវជូនដំណឹងជាសារធារណៈ[48] ឯកសារទាំងនេះត្រូវបានចាត់ទុកជាសម្ងាត់ ហើយ ជាផលវិបាក ឯកសារនេះ មិនអាចរំលែកជាមួយបុគ្គលដទៃនៅក្រៅតុលាការ ឬ មិនអាចដាក់បង្ហាញសម្រាប់សាធារណជនផងដែរ។ ដូចបានកត់សំគាល់នៅក្នុងការទំនាក់ទំនងរបស់មេធាវីការពារជាមួយ ក.ស.ច.ស[49]៖

> "វាពិតជាមិនអាចជាតួនាទីរបស់ផ្នែកសារព័ត៌មានរបស់ អ.វ.ត.ក ទេ ដើម្បីសម្រេចថាតើឯកសារណាមួយគឺជាឯកសារសាធារណៈ ហើយឯកសារណាមួយមិនមែនជាឯកសារសាធារណៈ ដោយផ្អែកលើតែឯកសារដែលដាក់នៅលើគេហទំព័ររបស់ អ.វ.ត.ក នោះ។ សំខាន់ជាងនេះទៅទៀត លោកអាចស្រាយបំភ្លឺ ប្រសិន

---

[46] ត្រូវបានកំណត់ថា "ទាក់ទងនឹង ឬ ការសន្និដ្ឋានរបស់ Franz Kafka ឬ ការសរសេររបស់គាត់: ជាពិសេស: មានសុបិនដ៏សាំញាំ, ចំឡែក ឬគុណភាពមិនសមហេតុផល។ សូមមើលគេហទំព័រ: http://www.merrium-webster.com.dictionary/kafkaesque.

[47] សូមមើលឧបសម្ពន្ធ ឆ: លិខិតឆ្លើយឆ្លងតាមអ៊ីម៉ែលរវាងលោក Geoff Robert ទីប្រឹក្សាច្បាប់ឲ្យក្រុមការពារ អៀង សារី និង លោក លី ចាន់ តុលា, ក្រឡាបញ្ជី ក.ស.ច.ស ។

[48] សូមមើល ឧទាហរណ៍ករណី អៀង សារី សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស សំណើចុះថ្ងៃទី ១៨ ខែកុម្ភៈ ២០០៩ ស្នើសុំការពន្លើនដើម្បីឲ្យលោក អៀង សារី បានពិនិត្យដោយអ្នកជំនាញវេជ្ជសាស្ត្រដែលមានគុណភាពខ្ពស់ និងឲ្យគាត់បន្តស្នាក់នៅ/បន្តឃុំខ្លួន នៅមន្ទីរពេទ្យ រហូតដល់គាត់បានជាសះស្បើយ ។ឯកសារនេះត្រូវបានជូនដំណឹងថាជាសាធារណៈ ប៉ុន្តែ វាមិនទាន់ដាក់បង្ហាញនៅលើគេហទំព័ររបស់ អ.វ.ត.ត នោះទេ។

[49] ឧបសម្ព័ន្ធ ឆ ។

បើ "សាធារណៈ" មានន័យថា ឯកសារមួយមិនអាចផ្សព្វផ្សាយទៅ ខាងក្រៅ ក.ស.ច.ស ឬអង្គបុរេជំនុំជម្រះ តបតាមការរៀបដាក់ឯកសារនោះ តែថា ឯកសារនេះ ត្រូវបានជូនដំណឹងទៅមនុស្សជាង៥០នាក់ ផ្សេងទៀតឯណោះ? ជាចុងក្រោយ ថាតើយ៉ាងម្ដេចដែរ សេចក្ដីសម្រេចរបស់ ក.ស.ច.ស ឬ អង្គបុរេជំនុំជម្រះថា ជាសាធារណៈ ហើយធ្វើសេចក្ដីយោង ទៅលើសារណាថា ឯកសារសាធារណៈអាចផ្សព្វផ្សាយនៅលើគេហទំព័ររបស់ អ.វ.ត.ក ដើម្បី ឲ្យសាធារណជនអាចពិនិត្យមើល ខណៈដែលសារណាដែលខ្លួនសំអាង ត្រូវបានចាត់ទុកថា ជាសម្ងាត់ទៅវិញ? ថាតើនេះមិនមែនរំលោភបំពានលើការសម្ងាត់នៃការស៊ើបសួរ ដែលព័ត៌មាន ត្រូវបានចាត់ទុកថា ជាការសម្ងាត់នោះឬ?

26. សំខាន់ជាងនេះទៅទៀត ការស្វែងរកការណែនាំពីមន្ត្រីតុលាការទៅលើឋានៈរបស់មេធាវីការពារស្ដីពីការដាក់ឯកសារ មានការលេចឮថា *"ក្រឡាបញ្ជីដាក់សេចក្ដីណែនាំពីការជូនដំណឹង ហើយបញ្ជូនវាមកឲ្យយើងខ្ញុំ។ យើងខ្ញុំរក្សាទុកអត្ថបទស្អែនសម្រាប់ដាក់កំណត់ត្រារបស់យើង ប៉ុន្តែមិនដាក់នៅក្នុង Zylab នោះទេ។ យើងខ្ញុំក៏បានដាក់អត្ថបទច្បាប់ដើម ព្រមជាមួយអត្ថបទ KH ជាក្រដាស់នៅក្នុងបណ្ណសារដ្ឋាន។ ហេតុដូច្នេះ ការដាក់ឯកសាររបស់ភាគីមិនបានឃើញសេចក្ដីណែនាំនៅចុងក្រោយ"*[50]។ អាស្រ័យហេតុនេះ សេចក្ដីសម្រេចរបស់ ក.ច.ស.ច ដើម្បីផ្លាស់ប្ដូរឋានៈរបស់សំណើពីសាធារណៈមកជាសម្ងាត់វិញ គឺមិនបានជូនដំណឹងដល់ភាគីដាក់ឯកសារ ហើយក៏មិនបានដាក់បញ្ចូលទៅក្នុងសំណុំរឿងដែរ ។

27. និយាយឲ្យសាមញ្ញទៅ ក.ស.ច.ស មិនបានសំអាងលើយុត្តិសាស្ត្រដែលអាចធ្វើយុត្តិកម្មដល់ការបកស្រាយរបស់ខ្លួនអំពីសារណាសាធារណៈ ជាសម្ងាត់ទៅវិញ។ តាមពិត វិធីសាស្ត្របកស្រាយដ៏ប្លែករបស់ ក.ស.ច.ស នៃការធ្វើយុត្តិកម្មបញ្ចប់របស់ខ្លួន នាំឲ្យចងចាំដល់ការកត់សំគាល់របស់ចៅក្រម David Hunt ទាក់ទងនឹងការបកស្រាយច្បាប់ពិបាកយល់ដោយសហការីរបស់គាត់នៅអង្គជំនុំជម្រះនៃសាលាឧទ្ធរណ៍របស់ ICTY[51]៖

*"ចៅក្រមជនជាតិអង់គ្លេសដែលទទួលការគោរពដ៏ខ្ពង់ខ្ពស់ លោក Lord Atkin កាលពីសម័យខ្មៅងងឹតនៃសង្គ្រាមលោកលើកទី២ នៅពេលសហការីប្អូននាក់របស់គាត់នៅសភាជាន់ខ្ពស់អង់គ្លេស ស្វែងរកជំហរស្រដៀង*

---

[50] សូមមើលឧបសម្ព័ន្ធ ជ: លិខិតឆ្លើយឆ្លងតាមអ៊ីម៉ែលរវាងលោក Geoff Robert ទីប្រឹក្សាច្បាប់ឲ្យក្រុមការពារ អៀង សារី និង លោក Christopher Fry មន្ត្រីកាន់សំណុំរឿងអន្តរជាតិរបស់តុលាការ ។

[51] រឿងក្ដីរវាងរដ្ឋអាជ្ញា តទល់ជាមួយ Slobodan Milosevic, IT-02-54-AR73.4 ការខ្វែងយោបល់របស់ចៅក្រម David Hunt ទៅលើភាពអាចទទួលយកបាននៃភស្តុតាងនៅក្នុងទម្រង់នៃសេចក្ដីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ(មានសំឡេងគាំទ្រលើសលុប ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៣។

*គ្នានេះ ពីប្រធានសភាជាន់ខ្ពស់ នៅពេលមានបកការស្រាយវិធានរបស់មេធាវីការពារ ដែលបំពេញចិត្តអង្គ នីតិប្រតិបត្តិ បាននិយាយពីការបកស្រាយដែលពួកគេបំពេញចិត្តនីតិប្រតិបត្តិ ថា*[52] ៖

> *ខ្ញុំដឹងថា មានអាជ្ញាធរតែមួយគត់ដែលអាចធ្វើយុត្តិកម្មលើវិធីសាស្ត្រដែលបានលើកឡើង, "នៅពេលខ្ញុំប្រើពាក្យ" Humpty, Dumpty ជំនួសឱ្យពាក្យប្រមាងមើលងាយ (Scornful) "មានន័យថា វាជាអ្វីដែលជ្រើសវាឱ្យមានន័យបែបហ្នឹង" "បញ្ហាគឺថា" លោក Alice ពោល "អ្នកអាចធ្វើពាក្យមួយ មានន័យខុសៗគ្នាច្រើន" "បញ្ហាគឺថា" Humpty, Dumpty ដែលជាចៅហ្វាយនាយ គឺមានតែប៉ុនហ្នឹង*[53]"។

28. មានការលេចឮតាមរយៈដីកាសម្រេចអំពីការរំលោភបំពានលើភាពសម្ងាត់ថា ក.ស.ច.ស ជឿជាក់ថាខ្លួនអាចជាន់ឈ្លីលើសិទ្ធិរបស់លោក អៀង សារី ដើម្បីបើកចំហដំណើរការនីតិវិធីឱ្យកាន់តែតម្លាភាព ក្នុងអំឡុងដំណាក់កាលស៊ើបសួរនេះ ដោយសារតែជាគោលការណ៍ "វាពាក់ព័ន្ធតែដំណាក់កាលរៀបចំតែប៉ុណ្ណោះ ហើយមិនអនុវត្តនៅដំណាក់សវនាការនោះទេ"[54]។ ការមិនខ្វាយខ្វល់លើនិយមន័យនៃ "ការជំនុំជម្រះដោយយុត្តិធម៌" និង ការព្រានចោលសិទ្ធិនៅដំណាក់កាលមុខអង្គសេចក្ដីនេះ បានឆ្លុះបញ្ចាំងឡើងវិញនូវវិធីសាស្ត្រលើកមុនៗរបស់ក.ស.ច.ស ចំពោះសិទ្ធិរបស់ជនជាប់ចោទដើម្បីចូលរួមការការពារដោយខ្លួនផ្ទាល់ ក្នុងអំឡុងពេលស៊ើបសួររបស់តុលាការ។ ឧទាហរណ៍ ឆ្លើយតបទៅនឹងសំណើរបស់ នួន ជា ស្នើសុំតែងតាំងអ្នកជំនាញការម្នាក់ ដើម្បីសម្រេចថាតើ គាត់មានសម្បទាដើម្បីចូលរួមសវនាការ[55] ក.ស.ច.ស យល់ឃើញថា បញ្ហាថាតើលោក នួន ជា មានសម្បទាគ្រប់គ្រាន់ដើម្បីចូលរួមសវនាការឬដែរយ៉ាងណានោះ "មិនកើតឡើងនៅដំណាក់កាលនេះទេ"[56]។ ម្យ៉ាងវិញទៀត គោលជំហររបស់ ក.ស.ច.ស គឺថា បើទោះបីជាជនត្រូវចោទម្នាក់ មិនមានសម្បទាដើម្បីចូលរួមសវនាការនៅដំណាក់កាលស៊ើបសួរនេះក៏ដោយ ក៏គាត់នៅតែស្ថិតនៅក្នុងមន្ទីរឃុំឃាំងដដែល ដោយគ្មានការធ្វើតេស្តផ្នែកវេជ្ជសាស្ត្រដើម្បីកំណត់អំពីសម្បទាផ្នែកស្មារតី ក៏ដូចជារូបរាងកាយរបស់គាត់។ ដំណាក់

---

[52] *សំណុំរឿង Liversidge តតាំងនឹង Anderson* [១៩៤២] AC 206 ទំព័រ ២៤៥

[53] ពីសៀវភៅកុមារដោយ Lewis Carroll, Alice *តាមរយៈការមើលកញ្ចក់* ជំពូកទី៦។ [ ចំណងជើងកាត់តែត្រឹមត្រូវថែមទៀតនោះ គឺតាមរយៈការមើលកញ្ចក់ និង អ្វីដែល Alice រកឃើញនៅទីនោះ (១៨៧១) ត្រូវបានបោះពុម្ពផ្សាយជារឿងភាគនៅមាតុភូមិរបស់ Alice នៅឆ្នាំ ១៨៦៥ ]

[54] ដីកាសម្រេចអំពីការរំលោភបំពានលើភាពសម្ងាត់ កថាខណ្ឌ ១១។

[55] ករណី នួន ជា សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស សំណើសុំតែងតាំងអ្នកជំនាញការ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០០៧ ។

[56] ករណី នួន ជា សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស លិខិតចុះថ្ងៃទី ១៤ ខែមិនា ឆ្នាំ២០០៨ ។

កាលស៊ើបសួរនេះ គឺអាចប្រើរយៈពេល ២ ទៅ ៣ ឆ្នាំ។ អង្គបុរេជំនុំជម្រះបដិសេធយ៉ាងខ្លាំងៗអំពីការបង្រួមឱ្យតូចនូវនិយមន័យរបស់សិទ្ធិនៃដំណាក់កាលមុនអង្គសេចក្តីនេះ[57]។ ហេតុដូច្នេះ វាបញ្ជាក់នឹងកាលៈទេសៈនេះ ដែលមេធាវីការពារស្នើសុំដោយគោរពថា ក.ស.ច.ស មិនអាច ហើយ មិនត្រូវបន្តរំលោភបំពានសិទ្ធិរបស់លោក អៀង សារី ក្នុងការទទួលបានកិច្ចដំណើរការនីតិវិធីជាសាធារណៈដោយក្តីសង្ឃឹមថា អង្គបុរេជំនុំជម្រះ នឹងកែតម្រូវកំហុសរបស់ ក.ស.ច.ស ដែលបានប្រព្រឹត្តក្នុងរយៈពេលកន្លងមកហើយ។

**ខ. ឯកសារដែលចោទថាសម្ងាត់ដែលដាក់បង្ហាញនៅលើគេហទំព័ររបស់មេធាវីការពារក្តីគឺគ្រាន់តែជាការសម្ងាត់ដើម្បីការពារសិទ្ធិរបស់លោក អៀង សារី ជាសិទ្ធិដែលគាត់អាចលះបង់បាន**

29. ចេតនានៅក្រោយការបង្កើតគេហទំព័ររបស់មេធាវីការពារក្តី គឺមិនដែលធ្វើឡើងដើម្បីលាតត្រដាងដោយខុសច្បាប់នូវព័ត៌មានសម្ងាត់ ដែលនឹងធ្វើអោយខូចខាតតាមវិធីណាមួយនៃការស៊ើបសួរ ឬវិធានការការពារណាមួយដែលបង្គាប់ដោយ ក.ស.ច.ស ឡើយ។ ផ្ទុយទៅវិញ ចេតនាគឺដើម្បីធ្វើអោយប្រសើរឡើងនូវមុខងារនៃការស៊ើបសួររបស់ ក.ស.ច.ស ដោយមានអំណះអំណាងថា ទិដ្ឋភាពដែលមិនមែនជាការសម្ងាត់នៃការស៊ើបសួរត្រូវពិនិត្យពិច្ច័យដោយសាធារណៈជន ។ ដូចដែលបានពន្យល់នៅក្នុងអ៊ីម៉ែលរបស់មេធាវីដែលបាននិយាយយោងខាងលើ ឆ្លើយឆ្លងជាមួយ ក.ស.ច.ស វាគឺជាចេតនារបស់មេធាវីការពារក្តី ដើម្បីគោរពតាមដីកាស្តីពីការសម្ងាត់ អោយបានកាន់តែធាប់ដើម្បីអោយបង្ហាញនូវភាពជាក់លាក់ខ្លះៗថា ការពិតឯកសារណាខ្លះត្រូវតែដកចេញពីគេហទំព័រ[58] ។

30. ចំពោះការដាក់ឯកសាររបស់មេធាវីការពារក្តីដែលថា ទំនងជាត្រូវបានជូនដំណឹងថាជាការសម្ងាត់ដែលត្រូវបានសម្រេចក្រោយមកដោយ អង្គបុរេជំនុំជម្រះ មេធាវីការពារក្តីកត់សម្គាល់ថា ទាំងនេះគឺទាក់ទងនឹងលក្ខខណ្ឌសុខភាពរបស់លោក **អៀង សារី** និងឥទ្ធិពលដែលវាមានមកលើទាំងការឃុំខ្លួនគាត់ និងទាំងលើលទ្ធភាពរបស់គាត់ដើម្បីចូលរួមក្នុងកិច្ចការពារក្តីរបស់គាត់ ។ ឯកសារទាំងនេះត្រូវបានដាក់ជូនជាសាធារណៈដោយមេធាវីការពារក្តី ដែលឆ្លុះបញ្ចាំងការពិតដែលថា លោក **អៀង សារី** បានលះបង់សិទ្ធិសិទ្ធិរបស់គាត់សំរាប់ការដាក់ឯកសារនានា ទាក់ទងនឹងបញ្ហាវេជ្ជសាស្ត្រនានាដែលត្រូវ

---

[57] ករណី អៀង សារី សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ទាក់ទងនឹងការចាត់តាំងអ្នកជំនាញម្នាក់ ចុះថ្ងៃទី២១ ខែ តុលា ឆ្នាំ២០០៨ កថាខណ្ឌ ៣៥ ។

[58] ឧបសម្ព័ន្ធ ឆ ។

វក្សាជាការសម្ងាត់[59] ។ បញ្ហាសុខភាពរបស់លោក **អៀង សារី** និងឥទ្ធិពលរបស់វាមកលើ*សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌* ដែលក្នុងចំណោមនោះ រួមបញ្ចូលសិទ្ធិចូលរួមក្នុងកិច្ចការពារខ្លួនរបស់គាត់ គឺជាបញ្ហាមួយដែលមេធាវីការពារក្តីបានលើកឡើងជាច្រំដែលៗ[60] ហើយត្រូវបានជជែក

[59] ឧបសម្ព័ន្ធ ឈ៖ លិខិតលះបង់សិទ្ធិរបស់លោក អៀង សារី សំរាប់ការពិភាក្សាអំពីស្ថានភាពសុខភាពរបស់គាត់ និងការដាក់ឯកសារនានាដោយមេធាវីការពារក្តីដែលត្រូវបានដាក់ជាសាធារណៈ ។

[60] ១) *ករណី អៀង សារី* សំណុំលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស អនុស្សារណៈអន្តរការិយាល័យ មានចំណងជើងថា "កិច្ចប្រជុំថ្ងៃទី ១៨ ធ្នូ ២០០៧" ចុះថ្ងៃទី ២០ ធ្នូ ២០០៧។ ២) *ករណី អៀង សារី* សំណុំលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស សំណើសុំការបកប្រែឯកសារទាំងអស់ដែលគាំទ្រដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ចុះថ្ងៃទី ១០ មករា ២០០៨ ។ ៣) *ករណី អៀង សារី* សំណុំលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ០៣) សំណើជាបន្ទាន់សុំអោយពន្យារពេលដ៏សមហេតុផលដើម្បីតតាំងនឹងបញ្ហាយុត្តាធិការ និងឆ្លើយតបតាមការអញ្ជើញរបស់អង្គបុរេជំនុំជម្រះអោយឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅលើបណ្តឹងឧទ្ធរណ៍ស្តីការឃុំខ្លួនបណ្តោះអាសន្ន ("ចម្លើយតបនឹងការអញ្ជើញរបស់អង្គបុរេជំនុំជម្រះ") ចុះថ្ងៃទី ១៨ កុម្ភៈ ២០០៨ ។ ៤) *ករណី អៀង សារី* សំណុំលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ០៣) សំណើសុំជាបន្ទាន់សុំអោយមានការបន្ថែមទំព័រ និងពេលវេលាកំណត់ ចុះថ្ងៃទី ១២ មីនា ២០០៨ ។ ៥) *ករណី អៀង សារី* សំណុំលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ០៣) សំណើរបស់លោក អៀង សារី សុំអោយផ្អាកការពិចារណាលើបណ្តឹងឧទ្ធរណ៍សុំអោយដាក់គាត់នៅក្នុងផ្ទះ ជំនួសអោយការឃុំឃាំងនៅមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក និងស្នើសុំអោយចេញដីកាបង្គាប់អោយ ក.ស.ចៅ.ស ដាក់លោក អៀង សារី នៅក្នុងមន្ទីរពេទ្យសំរាប់អំឡុងពេលនៃដំណាក់កាលនីតិវិធីស៊ើបសួរ ចុះថ្ងៃទី ១៣ មីនា ២០០៨ ។ ៦) *ករណី អៀង សារី* សំណុំលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស សំណើសុំរបស់អ្នកជំនាញចិត្តសាស្រ្តពិនិត្យលោក អៀង សារី ដើម្បីកំណត់ពីភាពសម្បទាដើម្បីចូលរួមការកាត់សេចក្តី ចុះថ្ងៃទី ១៤ មីនា ២០០៨ ។ ៧) *ករណី អៀង សារី* សំណុំលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស លិខិតមកកាន់ ក.ស.ចៅ.ស មានចំណងជើងថា កង្វះការឆ្លើយតបនឹងសំណើសុំអោយមានការបកប្រែរាល់ឯកសារគាំទ្រដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរជាភាសាខ្មែរ និងអង់គ្លេស ចុះថ្ងៃទី ៦ ឧសភា ២០០៨ ។ ៨) *ករណី អៀង សារី* សំណុំលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស លិខិតទៅកាន់ ក.ស.ចៅ.ស មានចំណងជើងថា "កង្វះការឆ្លើយតបនឹងសំណើរបស់អ្នកជំនាញចិត្តសាស្រ្តពិនិត្យលោក អៀង សារី ដើម្បីកំណត់ពីសម្បទាចូលការជំនុំជម្រះសេចក្តី" ដែលបានដាក់ថ្ងៃទី ១៤ មីនា ២០០៨ ចុះថ្ងៃទី ១៩ មិថុនា ២០០៨។ ៩) *ករណី អៀង សារី* សំណុំលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ០៣) កំណត់ហេតុសវនាការ ចុះថ្ងៃទី ៣០ មិថុនា ២០០៨ ។ ១០) *ករណី អៀង សារី* សំណុំលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ១៧) ចម្លើយតបរបស់លោក អៀង សារី សេចក្តីបង្គាប់របស់ អង្គបុរេជំនុំជម្រះ ទាក់ទងនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំអោយសម្រេចលើបណ្តឹងឧទ្ធរណ៍ត្រឹមតែសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ចុះថ្ងៃទី ១៩ មករា ២០០៩ ។ ១១) *ករណី អៀង សារី* សំណុំលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ១៧) សំណើរបស់លោក អៀង សារី សុំអោយកោះហៅអ្នកជំនាញវេជ្ជសាស្រ្តអោយផ្តល់ភស្តុតាងនាពេលសវនាការដេញដោលផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ៩ កុម្ភៈ ២០០៩ ។ ១២) *ករណី អៀង សារី* សំណុំលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ១៧) សំណើរបស់លោក អៀង

ដេញដោលយ៉ាងពេញទំហឹងនៅក្នុង*អង្គសវនាការជាសាធារណៈ* នៅចំពោះមុខអង្គបុរេជំនុំជម្រះ នាថ្ងៃទី ៣០ មិថុនា ២០០៨ ។ ហេតុដូច្នេះ ប្រហែលជាថា សេចក្តីសម្រេចធ្វើឡើងដោយ អង្គបុរេជំនុំជម្រះ ដើម្បីការពារសិទ្ធិនានារបស់លោក **អៀង សារី** នេះកំពុងត្រូវបានលេងល្បិចផ្អែក(manipulated) ដោយ ក.ស.ច.ស ដើម្បីដាក់ទណ្ឌកម្មដល់សហមេធាវីរបស់គាត់ ដែលកំពុងព្យាយាមការពារសិទ្ធិទាំងនេះ ។ គ្មានអ្វីគួរអោយឆ្ងល់ថា មេធាវីការពារក្តីទទួលស្គាល់ថា ក្រោមវិធាន ៥៦(១) ការសម្ងាត់ត្រូវបានធ្វើយុត្តិកម្មដើម្បី "រក្សាសិទ្ធិ និងផលប្រយោជន៍របស់ភាគី"។ ប៉ុន្តែ ការដាក់ឯកសារដែលទាក់ទងនឹងសុខភាពរបស់លោក **អៀង សារី** គ្រាន់តែប៉ះពាល់ត្រឹមតែសិទ្ធិ និងផលប្រយោជន៍របស់គាត់ប៉ុណ្ណោះ ហើយគាត់មិនមានបំណងប្រាថ្នាអោយវាជាការសម្ងាត់ឡើយ ដូច្នេះនេះវាធ្វើអោយបាត់បង់នូវភាពចាំបាច់ដើម្បីបន្តធ្វើយុត្តិកម្មលើចំណាត់ថ្នាក់នៃឯកសារទាំងនេះថាជាការសម្ងាត់។

31. មេធាវីការពារក្តី កត់សម្គាល់បន្ថែមទៀតថា បើសិនជាដីកាស្តីពីការសម្ងាត់ បានសំអាងលើក្តីបារម្ភដ៏ពិតប្រាកដ ចំពោះការផ្លាយចេញនូវព័ត៌មានសម្ងាត់ពីការស៊ើបសួរ ក.ស.ច.ស គួរតែបានក្រើនរំលឹកមេធាវីការពារក្តីភ្លាមមួយរំពេច អំពីក្តីកង្វល់របស់ខ្លួន ខណៈដែលគេហទំព័រទើបចាប់មានសកម្មភាព មិនបាច់រង់ចាំដើម្បីអោយដីកាស្តីពីការសម្ងាត់ ត្រូវបានបកប្រែអោយគ្រប់បីភាសានោះឡើយ។ ការពិតវាកាន់តែច្បាស់ខ្លាំងឡើងថា ក.ស.ច.ស បានសម្រេចរង់ចាំរហូតទាល់តែសហមេធាវីអន្តរជាតិរបស់លោក **អៀង សារី** លោក **ម៉ៃខលខាណាវ៉ាស់** (Michael G. Karnavas) ចាកចេញពីក្រុងភ្នំពេញ ដែលមុនពេលនេះគាត់បានធ្វើការងារនៅទីនេះចំនួន ៨ ថ្ងៃរួចមកហើយ ទើបបានដាក់ចេញសេចក្តីសម្រេចនេះ ឬ ក៏សូម្បីតែពិភាក្សាគ្នាលើបញ្ហានេះ នៅវេលាដែលគាត់កំពុងមានវត្តមាន ហើយជាមួយគ្នានឹងសហមេធាវីរបស់គាត់លោក **អាង ឧត្តម** អាចឆ្លើយតបយ៉ាងមានប្រសិទ្ធិភាពទៅនឹងការចោទប្រកាន់ទាំងនេះ។ ដោយការដាក់សេចក្តីសន្និដ្ឋាននេះនៅពេលវេលាជាក់លាក់ខណៈដែលលោក **ខាណាវ៉ាស់** កំពុងជិះនៅលើយន្តហោះត្រឡប់ទៅប្រទេសហូល្លង់វិញ សន្មតថា ការលៃពេលវេលាមិនមែនជារឿងចៃដន្យឡើយ តែជាការសម្រេចចិត្តមួយប្រកបដោយកលល្បិចដ៏ប៉ិនប្រសប់ (tactical maneuver) របស់ ក.ស.ច.ស.។

---

សារី សុំអោយដាក់បញ្ចូលបន្ថែមនូវរបាយការណ៍វេជ្ជសាស្ត្ររបស់ វេជ្ជបណ្ឌិត PAULUS FALKE ទៅក្នុងសំណុំរឿងនិងសំណើសុំអនុញ្ញាតអោយវេជ្ជបណ្ឌិត PAULUS FALKE ដើម្បីផ្តល់ភស្តុតាងតាមរយៈការផ្សាយបន្តផ្ទាល់តាមរូបភាពវីដេអូ (videolink)នាពេលសវនាការថ្ងៃទី ២៦ កុម្ភៈ ២០០៩ ចុះថ្ងៃទី ២០ កុម្ភៈ ២០០៩ ។

00287401



**គ. លិខិតព្រមានក្រុមមេធាវីការពារក្តីចំពោះចេតនាដើម្បីបង្កើតគេហទំព័រផ្ទាល់ខ្លួន និងផ្សព្វផ្សាយនូវការដាក់ឯកសារដោយខ្លួនឯក មិនបង្កើតជាសេចក្តីសម្រេច ឬបង្កើតបានជាការព្រមានអនុលោមតាមវិធាន ៣៨(១) ឡើយ**

32. ក.ស.ច.ស អះអាងនៅក្នុងដីកាស្តីពីការសម្ងាត់ ថាលិខិតចុះថ្ងៃទី ១៥ មករា ទាក់ទងនឹងចេតនារបស់មេធាវីការពារក្តីដើម្បីបង្កើតនូវគេហទំព័រមួយ បង្កើតបានជាសេចក្តីសម្រេចដែលមេធាវីការពារក្តីបានរំលោភបំពាន តាមរយៈការដាក់បង្ហាញឯកសារសម្ងាត់នៅលើគេហទំព័រ ។ ដើម្បីធ្វើយុត្តិកម្មនេះនូវការកែប្រែឈ្មោះពីលិខិត ទៅជាសេចក្តីសម្រេច ក.ស.ច.ស សំអាងទៅសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលពីមុនបានប្រកាសថាបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី គឺមិនអាចទទួលយកបាន ក្នុងការប្រឆាំងនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស ថ្វីបើការពិតដែលថាសេចក្តីសម្រេចនោះចេញមកពីទម្រង់ជាលិខិតមួយ[61] ។ ចំពោះ ក.ស.ច.ស ដែលទាញយកប្រយោជន៍ពីសេចក្តីសម្រេចរបស់ អង្គបុរេជំនុំជម្រះ ដែលស្វែងរកការការពារសិទ្ធិរបស់គូភាគីដើម្បីប្តឹងឧទ្ធរណ៍នឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស ថ្វីបើទម្រង់នៃសេចក្តីសម្រេច គឺមានតែភាពមិនស្មោះត្រង់។ ការពិត មេធាវីការពារក្តី ស្នើសុំថា បើសិន ក.ស.ច.ស មានបំណងប្រកាសថា មេធាវីការពារក្តី បានរំលោភបំពានលើសេចក្តីសម្រេច នៅក្នុងរបៀបដែលត្រឹមត្រូវតាមនីតិវិធី ដើម្បីគូសបញ្ជាក់ថា "សេចក្តីសម្រេច" ជាក់លាក់ត្រូវបានគេរំលោភបំពាន។ ក.ស.ច.ស មិនគួរស្វែងរកទាញអត្ថប្រយោជន៍ពីយុត្តិសាស្ត្ររបស់ អង្គបុរេជំនុំជម្រះ ដែលមានចេតនាដើម្បីការពារគូភាគីប្រឆាំងនឹងការរំលោភបំពានដោយ ក.ស.ច.ស ។

33. បន្ថែមពីនេះទៀត មេធាវីការពារក្តីកត់សម្គាល់ថា ក្រោមវិធាន ៣៨(១) ក.ស.ច.ស ឬ អង្គជំនុំជម្រះអាចដាក់ទណ្ឌកម្មទៅលើមេធាវីណាម្នាក់ "បន្ទាន់ពីការការព្រមានមួយ" ។ នៅក្នុងលិខិតចុះថ្ងៃទី ១៥ មករា មិនមានការយោងទៅកាន់វិធាន ៣៨(១) និងមិនមានការព្រមានជាក់លាក់ណាមួយត្រូវបានធ្វើឡើងនៅក្នុងអត្ថបទនៃលិខិត អំពីផលវិបាកនឹងមានឡើង បើសិនការព្រមាននោះមិនត្រូវបានគេយកចិត្តទុកដាក់។ ការព្រមាននេះនឹងអនុញ្ញាតអោយមេធាវីការពារក្តី ដើម្បី "ស្វែងរកឱកាសដើម្បីផ្លាស់ប្តូរ [...] កាលៈទេសៈ ថាតើបណ្តាលមកពីកំហុសវិជ្ជាជីវៈដោយចេតនា ឬកត្តាអចេតនា ដូច្នេះហើយដើម្បី

---

[61] *ករណី អៀង សារី* សំណុំលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ០៥) សេចក្តីសម្រេចស្តីភាពទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ដែលធ្វើឡើងដោយលោក អៀង សារី ស្តីពីសិទ្ធិជួបសួរសុខទុក្ខ ចុះថ្ងៃទី ២១ មីនា ២០០៨ ។

ជៀសវាងចុះចាញ់បង់សិទ្ធិទាំងនោះ" [62]។ ផ្ទុយទៅវិញ ក.ស.ច.ស ទំនងជាយកជាសំអាងដោយមានអានុភាពប្រតិសកម្មមកលើលិខិតនេះ ដែលជាជំហាននីតិវិធីតម្រូវមួយ ក្នុងការដាក់ចេញនូវទណ្ឌកម្ម តាមវិធាន ៣៨ ។ ការខកខានរបស់ ក.ស.ច.ស ដើម្បីគោរពទៅតាមវិធានរដ្ឋបាលក្នុងការចេញនូវការព្រមាន បង្កើតបានជាការខ្វះចន្លោះដ៏ធ្ងន់ធ្ងរ ហេតុដូច្នេះហើយដីកាស្តីពីការសម្ងាត់ ដាច់ខាតត្រូវតែបដិសេធចោលដោយសារភាពមិនប្រក្រតីខាងនីតិវិធី។

**ឃ.ការខកខានរបស់ ក.ស.ច.ស និង អង្គបុរេជំនុំជម្រះ ក្នុងការដាក់ទណ្ឌកម្មទៅលើការរំលោភបំពានដោយខ្លួនឯងជាបន្តបន្ទាប់ ទៅលើកាតព្វកិច្ចរក្សាភាពសម្ងាត់របស់ខ្លួន បង្ហាញនូវការរើសអើងក្នុងប្រព្រឹត្តទៅខាងមេធាវីការពារក្តី និង អង្គភាពនានារបស់ អ.វ.ត.ក**

34. វាធ្វើអោយគេចាប់អារម្មណ៍ថា ក.ស.ច.ស បានព្យាយាមចំណាយពេលវេលា និងថាមពលដ៏ច្រើនគគោក ដើម្បីដាក់ទណ្ឌកម្មមេធាវីការពារក្តីចំពោះការផ្សព្វផ្សាយនូវព័ត៌មានដែលចោទថាជាការសម្ងាត់ នៅលើគេហទំព័រខ្លួន ខណៈដែលវាប្រហែលជាការទទួលខុសត្រូវចំពោះការរំលោភបំពានធ្ងន់ធ្ងរជាងផ្សេងៗគ្នានេះចំពោះការរំលោភបំពានការសម្ងាត់ដោយខ្លួនឯង។ នៅក្នុងវិធីជាគោលការណ៍ពីរ ក.ស.ច.ស បានរំលោភបំពាននូវការសម្ងាត់នៃការស៊ើបសួរ នៅក្នុងវិធីដែលធ្ងន់ធ្ងរជាងឆ្ងាយណាស់ជាងការដែលគេសន្មតថាវាត្រូវបានរំលោភបំពានដោយមេធាវីការពារក្តី។ ហេតុដូច្នោះហើយ ក្រោមគោលការណ៍នៃការប្រព្រឹត្តដោយស្មើភាពគ្នា ដែលបង្កើតឡើងតាមមាត្រា ២១(១)(ខ) មេធាវីការពារក្តីសូមដាក់ស្នើថា ឧទាហរណ៍នៃការរំលោភបំពានការសម្ងាត់ដោយ ក.ស.ច.ស គួរត្រូវបានគេស៊ើបអង្កេតដូចគ្នាដោយឆន្ទះមោះមុតដូចគ្នា។

35. ដំបូង វាបានស្តែងអោយឃើញថា សហចៅក្រមស៊ើបអង្កេត បានអនុញ្ញាតអោយក្រុមអ្នកថតកុន

---

[62] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Šešelj* សំណុំរឿង IT-03-67-AR73.3 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចស្តីពីការតែងតាំងមេធាវី ចុះថ្ងៃទី ២០ តុលា ២០០៦ កថាខណ្ឌ ២៣។ ចម្ងល់ក៏កើតមានផងដែរថា មេធាវីគួរទទួលបានសវនាការមួយទៅលើដីកាសម្រេចមួយដើម្បីបង្ហាញពីមូលហេតុដែរឬទេ នៅមុនពេលមានការដាក់ទណ្ឌកម្ម ។ *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Cypru* សំណុំរឿងលេខ 73797/01 តុលាការសិទ្ធិមនុស្សអឺរ៉ុប ចុះថ្ងៃទី ២៧ មករា ២០០៤ នៅពេលដែល តុលាការសិទ្ធិមនុស្សអឺរ៉ុប បានបដិសេធចោលនូវការផ្តន្ទាទោសចំពោះការប្រមាថតុលាការ និងរំលាយចោលនូវការផ្តន្ទាទោសចំនួន ៥ថ្ងៃ ដែលដាក់មកលើមេធាវីម្នាក់ដែលត្រូវបានគេកាត់ទោសយ៉ាងទាន់ហន់ដោយគ្មានដំណើរការក្តីត្រឹមត្រូវ ដោយសារតែចៅក្រមនាពេលសវនាការទទួលការប្រមាថនៅពេលដែលមេធាវីនោះខឹងក្រេវក្រោធ និងឈ្លោះជាមួយចៅក្រមទាំងនោះ។

បាំងអាចចូលមកថតខ្សែភាពយន្តអំពីការស៊ើបសួរ ។ តាមវិធាន ៥៦(២)(ខ) ក.ស.ច.ស មានកាតព្វកិច្ចដើម្បីស្នើសុំយោបល់ពីភាគី មុនពេលអនុញ្ញាតអោយទៅអោយសារព័ត៌មាន។ តាមការយល់ដឹងរបស់ មេធាវីការពារក្តី យោបល់របស់ភាគីមិនត្រូវបានគេស្តាប់ឡើយ។ ការពិត វាមិនមានការច្បាស់លាស់ថា តើកិច្ចសន្យាមួយអាចនឹងកើតមានដែរឬទេរវាង ក.ស.ច.ស និងក្រុមអ្នកថតភាពយន្តដែលអ្នកទាំងនោះត្រូវបានផ្តល់ការអនុញ្ញាតទទួលព័ត៌មានដ៏លំអិតផ្ទៃក្នុងនៃការស៊ើបសួរ ។ បើសិនជាកិច្ចសន្យានោះត្រូវបានចុះហត្ថលេខា វាមិនមានភាពច្បាស់លាស់ស្មើគ្នាថាកំរិតណានៃការការពារត្រូវបានផ្តល់អោយចំពោះព័ត៌មាននៅក្នុងសំណុំរឿង ។ ជាអប្បបរិមា ទាក់ទងនឹងចំណុចនេះ ក.ស.ច.ស គួរក្លាយមកជាស្អាតស្អំ។

36. ទីពីរ វាលេចចេញមកពីព័ត៌មាននៅក្នុងផ្នែកសាធារណៈដែល ក.ស.ច.ស បានផ្ញើរចេញនូវដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង **ឌុច** ដោយគ្មានកាត់ចេញផ្នែកខ្លះ ទៅអោយអង្គការសង្គមស៊ីវិលដោយមិនបានប្រាប់ពួកគេថាវាការសម្ងាត់ ។ ដីកានេះត្រូវបានដាក់បង្ហាញជាបន្តបន្ទាប់លើគេហទំព័រផ្សេងៗ និងបានរួមបញ្ចូលនូវឈ្មោះរបស់សាក្សីដែលត្រូវបានការពារ។ ខណៈគ្មានសួរដេញដោលពីកំហុសរបស់សមាជិកម្នាក់របស់ ក.ស.ច.ស គេបែរជាធ្វើការសន្មតថាមេធាវីការពារក្តីរំលោភបំពានលើការសម្ងាត់ទៅវិញ។ តាមការប្រៀបធៀប មេធាវីការពារក្តីបានត្រឹមតែផ្សព្វផ្សាយនូវការដាក់ឯកសារនានារបស់ខ្លួនប៉ុណ្ណោះ ដែលទាក់ទាំងស្រុងតែទៅលើបញ្ហាអង្គច្បាប់ ហើយ<u>មិនដែល</u>យោងទៅរកព័ត៌មានសម្ងាត់របស់សំណុំរឿងឡើយ។ ដោយព្យាយាមដាក់ទណ្ឌកម្មមេធាវីការពារក្តី ចំពោះទង្វើនេះ ដែលធ្វើឡើងក្នុងគោលបំណងដើម្បីផ្តល់កាន់តែទូលំទូលាយថែមទៀតដល់តម្លាភាព និងការពិនិត្យពិច័យរបស់សាធារណៈជនចំពោះកិច្ចដំណើរការនីតិវិធី ធ្វើអោយគេមានគំនិតកាន់តែខ្លាំងថា ក.ស.ច.ស កំពុងបញ្ចៀសនូវការចាប់អារម្មណ៍ចំពោះការខកខាន និងការរំលោភបំពានការសម្ងាត់របស់ខ្លួន។

## VII. សេចក្តីសន្និដ្ឋាន និងសំណូមពរ

37. សូមស្នើដោយក្តីគោរពថា មេធាវីការពារក្តី បានធ្វើត្រឹមតែ៖ បង្កើតអោយសាធារណៈជនអាចទទួលបានគ្រប់អំណះអំណាងទាំងអស់ក្នុងនាមលោក **អៀង សារី** ដែលផ្ទុកនូវព័ត៌មានដែលមិនមែនជាការសម្ងាត់ ក្នុងគោលបំណងដើម្បីការពារ និងលើកតម្កើង*សិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌*ដែលត្រូវការពារដោយរដ្ឋធម្មនុញ្ញ របស់លោក **អៀង សារី** ។

អាស្រ័យដោយហេតុផលទាំងអស់ដែលបានលើកឡើងនៅទីនេះ មេធាវីការពារក្តីសូមស្នើដោយក្តីគោរព ដល់ អង្គបុរេជំនុំជម្រះ សូមមេត្តា៖

ក. **អនុញ្ញាតទទួលយក**បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី ប្រឆាំងនឹងដីកាសម្រេចស្តីពីការរំលោភបំពានភាពសម្ងាត់នៃការស៊ើបសួរ ចុះថ្ងៃទី ៣ មីនា ២០០៩

ខ. **ទុកជាមោឃៈ**នូវដីកាស្តីពីការសម្ងាត់ ធ្វើនៅថ្ងៃទី ៣ មីនា ២០០៩

គ. **អនុញ្ញាត**អោយមេធាវីការពារក្តី រក្សានូវគេហទំព័ររបស់ខ្លួនគ្រប់ពេលវេលានៅគ្រប់កិច្ចដំណើរការនីតិវិធីរបស់ អ.វ.ត.ក ដែលដាក់ផ្សាយបង្ហាញនូវការដាក់ឯកសារសាធារណៈនានារបស់មេធាវីការពារក្តីនៅចំពោះមុខ អ.វ.ត.ក ជាមួយគ្នានឹងសេចក្តីសម្រេចជាសាធារណៈនានាដែលសម្រេចអំពីការដាក់ឯកសារនោះ

ឃ. **បង្គាប់អោយ**ភាគីនានានៅក្នុងសំណុំរឿង ០០២ ឆ្លើយតបនឹងបណ្តឹងឧទ្ធរណ៍ក្នុងរយៈពេល ៧ ថ្ងៃនៃថ្ងៃជូនដំណឹង

ង. **កំណត់កាលបរិច្ឆេទ**សវនាការដេញដោលផ្ទាល់មាត់នាថ្ងៃទី ៣ មេសា ២០០៩

ច. **បង្គាប់**ថាសេចក្តីសន្និដ្ឋាននេះត្រូវផ្សព្វផ្សាយលើគេហទំព័ររបស់ អ.វ.ត.ក ភ្លាម ។

សូមអង្គបុរេជំនុំជម្រះទទួលយកបណ្តឹងឧទ្ធរណ៍នេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **១០** ខែ**មីនា** ឆ្នាំ **២០០៩**

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**អាង ឧត្តម** Michael G. KARNAVAS

សហមេធាវីរបស់លោក **អៀង សារី**